សហភាពអឺរ៉ុប

**សហភាពអឺរ៉ុប កម្មវិធីស្បៀងអាហារ**

**FAO EU Food Facility Project**

FAO EU FFP-I 01

# ការរៀបចំ ក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក កិច្ចដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្ត្រ






រៀបចំដោយ:

## មជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ

ខែមិថុនា ២០១១

# សេចក្តីថ្លែងអំណរគុណ

ឯកសារបណ្តុះបណ្តាលស្តីពី **ការរៀបចំសហគមន៍/ក្រុមកសិករប្រើប្រាស់ទឹក កិច្ចដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្ត្រ** បានរៀបចំចងក្រងឡើងក្រោមការឧបត្ថម្ភគាំទ្រពី **កម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប** “FAO EU Food Facility Project “ ដែលជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នារវាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងក្រសួងធនធានទឹក និងឧតុនិយម និង ជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ (TSC) ។ គម្រោងនេះបានផ្តល់ថវិកា ដោយសហភាពអឺរ៉ុប ។

ប្រភពធនធានមនុស្សដែលបានចូលរួមជួយរៀបរៀងចងក្រង ផ្តល់យោបល់ និងកែលម្អឯកសារបណ្តុះបណ្តាលនេះឡើង រួមមានមន្ត្រីជំនាញរបស់មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល គ្រូបង្គោល ទីប្រឹក្សាបច្ចេកទេសជាតិ និងអន្តរជាតិ នៃគម្រោងកម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប និងមន្ត្រីនៃមន្ទីរធនធានទឹក និង ឧតុនិយមខេត្ត ក្នុងការរៀបចំក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក ក្នុងខេត្តគោលដៅទាំង ១០ (ខេត្តកំពង់ស្ពឺ តាកែវ ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ និង ព្រះវិហារ) ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មន្ត្រីពាក់ព័ន្ធទាំងអស់ មន្ត្រីបច្ចេកទេសរបស់មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ (TSC) នៃក្រសួងធនធានទឹក និង ឧតុនិយម ដែលបានចំណាយពេលវេលាក្នុងការរៀបចំឯកសារបណ្តុះបណ្តាលសហគមន៍/ក្រុមកសិករប្រើប្រាស់ទឹក កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រនេះ ដែលមានលក្ខណៈសមស្របសម្រាប់ប្រើប្រាស់ជាឯកសារយោង ក្នុងការចងក្រង និងពង្រឹងក្រុមកសិករប្រើប្រាស់ទឹក ។

# អារម្ភកថា

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម ក្រោមកិច្ចសហការ និងគាំទ្រដោយកម្មវិធីស្បៀងអាហារ របស់សហភាពអឺរ៉ុប បានរៀបចំគម្រោងបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករដែល រងឥទ្ធិពលដោយការឡើងថ្លៃនៃស្បៀងអាហារ។ គំរោងនេះមានគោលដៅដើម្បីពង្រឹងវិស័យកសិកម្ម និងអាហារូបត្ថម្ភនៅតាមសហគមន៍តាមជនបទ។ ការចងក្រង និងពង្រឹងក្រុមកសិករប្រើប្រាស់ទឹកឱ្យមានភាពជាម្ចាស់លើការគ្រប់គ្រង និងការថែទាំប្រព័ន្ធធារាសាស្ត្រ ដែលបានកសាងឡើងដោយគម្រោងខាងលើធានាការផ្គត់ផ្គង់ទឹកស្រោចស្រពសម្រាប់ដំណាំកសិកម្ម និងធានានិរន្តរភាពប្រពន្ធ័ធារាសាស្ត្រ។

ឯកសារស្តីពី **ការរៀបចំក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក និងឯកសារស្តីពី កិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ** ត្រូវបានរៀបចំឡើងសម្រាប់ជាឯកសារយោង ជួយដល់មន្ត្រីជំនាញ ក៏ដូចជាសមាជិកគណៈកម្មការក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក ក្នុងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រឱ្យមានប្រសិទ្ធិភាព និងនិរន្តរភាព ស្របតាមសារាចរ ០១ របស់រាជរដ្ឋាភិបាលកម្ពុជា និងប្រកាស ៣០៦ របស់ក្រសួងធនធានទឹក និងឧតុនិយម។

មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកម្មវិធីស្បៀងអាហាររបស់សហភាពអឺរ៉ុប និងអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ ដែលបានផ្តល់ការគាំទ្រផ្នែកថវិកាលើការចងក្រង និងការបោះពុម្ពឯកសារខាងលើសម្រាប់មន្ត្រីជំនាញ គណៈកម្មការក្រុមកសិករប្រើប្រាស់ទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ប្រើប្រាស់ជាមូលដ្ឋានចំណេះដឹងក្នុងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រឱ្យមានប្រសិទ្ធិភាពខ្ពស់ និងនិរន្តរភាព។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១១

**ប្រធានគ្រប់គ្រងគម្រោង**

**ទឹម អេឃឹន**

**អគ្គនាយករង កិច្ចការរដ្ឋបាល**
**និងជាប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេស**
**ប្រព័ន្ធធារាសាស្ត្រឧតុនិយម**

**ពេជ្រ ខាសនា**

# មាតិកាអត្ថបទ

អារម្ភកថា ទំព័រ


**ផ្នែកទី ១- ការរៀបចំក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក** ១

- ដំណាក់នៃការបង្កើត ក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក ១

**ផ្នែកទី ២- កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ** ៧

១- លក្ខណៈទូទៅនៃប្រព័ន្ធធារាសាស្ត្រ ៧

២- អត្ថប្រយោជន៍នៃប្រព័ន្ធធារាសាស្ត្រ ៧

៣- បញ្ហារួមចំពោះប្រព័ន្ធធារាសាស្ត្រ ៨

៤- ប្រភពទឹកស្រោចស្រព ៩

៥- ប្រភេទប្រព័ន្ធធារាសាស្ត្រ ៩

**ផ្នែកទី ៣- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ** ១៥

១-សេចក្តីផ្តើម ១៥

២- ការគ្រប់គ្រងសំណង់ធារាសាស្ត្រ ១៥

៣- ការគ្រប់គ្រងទឹកសម្រាប់ស្រោចស្រព ១៥

**ផ្នែកទី ៤- កិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ** ១៩

១- កិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ ១៩

២- និតិវិធីនៃការបែងចែកទឹក ១៩

៣- តុល្យភាពទឹក ២០

៤- ការប្រើប្រាស់សំណង់ធារាសាស្ត្រ ២០

៥- វិធីសាស្ត្រក្នុងការបិទ រឺ បើកទ្វារទឹក ២០

**ផ្នែកទី ៥- ការជួសជុល និង ថែទាំប្រព័ន្ធធារាសាស្ត្រ** ២២

១- សេចក្តីផ្តើម ២២

២- ដំណើរការជួសជុល និង ថែទាំអាងទឹក ២២

៣- ការជួសជុល ២៣

៤- ដំណើរការថែទាំក្បាលហុងទឹក ២៥

៥- ដំណើរការថែទាំសំណង់បង្ហៀរ ២៦

៦- ដំណើរការថែទាំប្រឡាយមេ និង ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រឡាយមេ ២៧

៧- សំណង់សិល្បៈការក្នុងប្រឡាយ ២៩

៨- ការងារធ្វើរបាយការណ៍ ៣៣

៩- ការរៀបចំផែនការជួសជុល និង ថែទាំ ៣៣

## ផ្នែកទី ៦- ការរៀបចំថវិកាសម្រាប់ថែទាំ


១-ការទទួលខុសត្រូវនៃការរៀបចំផែនការថែទាំ ៣៥

២- ការគ្រប់គ្រងហិរញ្ញវត្ថុ ៣៦

៣- សវនកម្មនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ៣៨

៤- ផែនការសេវាកម្មស្រោចស្រព និង ថ្លៃសេវាកម្មស្រោចស្រព ៣៨

៥- ការគ្រប់គ្រងរដ្ឋបាល ក.ក.ប.ទ / ស.ក.ប.ទ ៤០


## ផ្នែកទី ៧- ឧបសម្ព័ន្ធ


១- ឧបសម្ព័ន្ធទី១- ការសរសេរលិខិតរដ្ឋបាល ៤២

២- ឧបសម្ព័ន្ធទី២- គំរូលិខិតប្រធានគណៈកម្មាការ ស.ក.ប.ទ ៤៧

៣- ឧបសម្ព័ន្ធទី៣- របាយការណ៍ ៤៨

៤- ឧបសម្ព័ន្ធទី៤- របាយការណ៍បូកសរុប ៤៩

៥- ឧបសម្ព័ន្ធទី៥- របាយការណ៍សង្ខេប បេសកកម្មរបស់ ស.ក.ប.ទ ៥០

៦- ឧបសម្ព័ន្ធទី៦- លិខិតអញ្ជើញ ៥១

៧- ឧបសម្ព័ន្ធទី៧- យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា លើវិស័យធារាសាស្ត្រ ៥២

# ផ្នែកទី ១. ការរៀបចំ ក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក

## ជំហាននៃការបង្កើត ក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក

សម្រាប់ដំណើរការរៀបចំក្រុម/សហគមន៍ កសិករប្រើប្រាស់ទឹក រួមមានប្រាំបីជំហានសំខាន់ៗដូចខាងក្រោម៖

(ក្រុមកសិករប្រើប្រាស់ទឹក សរសេរអក្សរកាត់ គឺ ក.ក.ប.ទ សហគម ន៍កសិករ ប្រើប្រាស់ទឹក សរសេរអក្សរកាត់ ស.ក.ប.ទ)

### ជំហានទី ១: ប្រារព្ធកិច្ចប្រជុំដំបូងនៅក៏រិតប្រព័ន្ធធារាសាស្ត្រ

១ ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ ប្រារព្ធកិច្ចប្រជុំឡើងដើម្បីណែនាំអំពី ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល និង កិច្ចអភិវឌ្ឍក្នុងវិស័យធារាសាស្ត្រកសិកម្ម PIMD ( មន្ត្រីមកពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ) ។

២ ប្រារព្ធកិច្ចប្រជុំវាយតំលៃមូលដ្ឋានដោយមានការចូលរួមដើម្បីរកបញ្ហាលំបាក និង ឱកាសសំរាប់អភិវឌ្ឍកសិកម្ម និង ធារាសាស្ត្រ ។

៣ ប្រជុំដើម្បីរៀបផែនការជំហានបន្ទាប់ ។

*ខាងក្រោមនេះគឺជាប្រធានបទនៃការពិភាក្សាក្នុងកិច្ចប្រជុំណែនាំកសិករមុនពេលបង្កើត ក.ក.ប.ទ/ស,ក,ប,ទ*

១ ពិភាក្សាអំពីគោលបំណង និង ទិសដៅរបស់កសិករ និង បញ្ហាលំបាកសំរាប់កសិកម្ម និង ជាពិសេសការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ។

២ ពិភាក្សាអំពីជំរើសនានាដើម្បីជំនះបញ្ហាលំបាកក្នុងកសិកម្ម និង ជាពិសេសក្នុងការគ្រប់គ្រង ធារាសាស្ត្រ ។

៣ ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ ពន្យល់អំពីគោលនយោបាយ កម្មវិធីរបស់ PIMD និង ហេតុផលដែលត្រូវមាន ។

៤ ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ កសិករ និង មេដឹកនាំមូលដ្ឋានពិភាក្សាគ្នាអំពីអត្ថប្រយោជន៍ កាតព្វកិច្ច និង ជំហានក្នុងដំណើរការរៀបចំ ក.ក.ប.ទ/ស,ក,ប,ទ ។

៥ ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ កសិករ និង មេដឹកនាំមូលដ្ឋានរៀបចំផែនការជំហានបន្ទាប់ សំរាប់រៀបចំ ក.ក.ប.ទ/ស,ក,ប,ទ ។

### ជំហានទី ២: រកតំបន់សេវាកម្មប្រព័ន្ធធារាសាស្ត្រ និង អនាគតសមាជិក ក.ក.ប.ទ/ស,ក,ប,ទ

១ រកព្រំប្រទល់ទឹកសំរាប់បង្កើត ក.ក.ប.ទ/ស,ក,ប,ទ និង អនុតំបន់វា

២ រកឈ្មោះអនាគតសមាជិក ក.ក.ប.ទ/ស,ក,ប,ទ និង អង្គភាពរងនីមួយៗ

៣ ពិភាក្សានិងធ្វើកិច្ចព្រមព្រៀងបឋមអំពីលក្ខណៈវិនិច្ឆ័យរបស់សមាជិកភាពក្នុង ក.ក.ប.ទ/ស,ក,ប,ទ

**ជំហានទី ៣: កសិករយល់ព្រមបង្កើត ក.ក.ប.ទ/ស.ក.ប.ទ និង រៀបចំផែនការសកម្មភាពបង្កើតកិច្ចការ**

១ ប្រជុំដើម្បីពិភាក្សា និង ធ្វើសេចក្តីសំរេចចិត្តលើការងារបង្កើត ក.ក.ប.ទ/ស.ក.ប.ទ

២ រៀបចំផែនការសកម្មភាព PIMD ដោយមានការចូលរួម

៣ យល់ព្រមលើសកម្មភាពកសិករដើម្បីបង្កើត ក.ក.ប.ទ/ស.ក.ប.ទ

បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការព្រាងលក្ខន្តិកៈ ក.ក.ប.ទ/ស.ក.ប.ទ ប្រជុំដើម្បីពិភាក្សាអំពីតួនាទី និង លក្ខណៈសម្បត្តិរបស់អ្នកជំនួយការ ក.ក.ប.ទ/ស.ក.ប.ទ ការជ្រើសរើសអ្នកជំនួយការ ក.ក.ប.ទ/ស.ក.ប.ទ ដោយគណៈកម្មាធិការព្រាងលក្ខន្តិកៈ ក.ក.ប.ទ/ស.ក.ប.ទ ការបណ្តុះបណ្តាលជាបឋមដល់អ្នកជំនួយការ ក.ក.ប.ទ/ស.ក.ប.ទ និង ការរៀបចំផែនការ ការងាររបស់គេ

**ជំហានទី ៤: កសិកររៀបចំ និង អនុម័តលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង ក.ក.ប.ទ/ស.ក.ប.ទ**

១ ណែនាំ និង បណ្តុះបណ្តាលសមាជិករបស់គណៈកម្មាធិការព្រាងអំពីទិដ្ឋភាពផ្លូវច្បាប់ គ្រប់គ្រង និង រៀបចំ ក.ក.ប.ទ/ស.ក.ប.ទ និង PIMD

២ គណៈកម្មាធិការបញ្ចប់សេចក្តីព្រាងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង

៣ ធ្វើសេចក្តីព្រាងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងត្រូវពិនិត្យឡើងវិញ និង យល់ព្រមដោយក្រុមទ្រទ្រង់ ក.ក.ប.ទ/ស.ក.ប.ទ ធ្វើសេចក្តីព្រាងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងត្រូវពិភាក្សា និង កែតំរូវឡើងវិញក្នុងកិច្ចប្រជុំទូទៅរបស់អនាគតសមាជិក

៤ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងដែលបានកែតំរូវ និង ព្រមព្រៀងហើយត្រូវចុះហត្ថលេខាដោយអនាគតសមាជិក ក.ក.ប.ទ/ស.ក.ប.ទ ទាំងអស់

៥ ចុះបញ្ជីសមាជិក

ខាងក្រោមនេះគឺជាខ្លឹមសារនានាដែលតែងតែបញ្ចូលក្នុងលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង ក.ក.ប.ទ/ស.ក.ប.ទ :

១ សេចក្តីថ្លែងការណ៍របស់ ក.ក.ប.ទ/ស.ក.ប.ទ ដើម្បីជាគោលបំណង និង វិសាលភាពរបស់ ក.ក.ប.ទ/ស.ក.ប.ទ

២ រចនាសម្ព័ន្ធ និង មុខងារជាមូលដ្ឋាន តើអ្វីជាមុខងារជាមូលដ្ឋានរបស់ ក.ក.ប.ទ/ស.ក.ប.ទ? តើអ្វីជារចនាសម្ព័ន្ធស្ថាប័ន និង គោលជំហររបស់ ក.ក.ប.ទ/ស.ក.ប.ទ?

៣ ឋានៈផ្លូវច្បាប់ និង មូលដ្ឋានអាជ្ញាធរ តើអ្វីជាឋានៈផ្លូវច្បាប់ អំណាចផ្លូវច្បាប់ និង កំរិតនៃអាជ្ញាធរ របស់ ក.ក.ប.ទ/ស.ក.ប.ទ ?

៤ ដែនសមត្ថកិច្ច តើអ្វីជាព្រំប្រទល់នៃប្រព័ន្ធធារាសាស្ត្រ និង អ្វីជារចនាសម្ព័ន្ធត្រូវបញ្ចូលក្នុងសមត្ថកិច្ច របស់ ក.ក.ប.ទ/ស.ក.ប.ទ?

៥ លក្ខណៈវិនិច្ឆ័យសំរាប់សមាជិកភាព តើនណារជាសមាជិករបស់ ក.ក.ប.ទ/ស,ក,ប,ទ និង តើគេត្រូវមាន លក្ខខណ្ឌអ្វីដើម្បីក្លាយជាសមាជិក?

៦ ការទទួលខុសត្រូវ និង សិទ្ធិជាមូលដ្ឋានរបស់ ក.ក.ប.ទ/ស,ក,ប,ទ តើអ្វីជាការទទួលខុសត្រូវ និង សិទ្ធិជា មូលដ្ឋានរបស់ ក.ក.ប.ទ/ស,ក,ប,ទ ជាអង្គភាពប្រមូលផ្តុំមួយ និង តើអ្វីជាសិទ្ធិ និង ការទទួល ខុសត្រូវរបស់ សមាជិកម្នាក់ៗ?

៧ រចនាសម្ព័ន្ធដឹកនាំ តើមានដំណែងអ្វីខ្លះនៅក្នុង ក.ក.ប.ទ/ស,ក,ប,ទ?

៨ វិធីសាស្ត្រសំរាប់ធ្វើវិសោធនកម្មច្បាប់បញ្ញត្តិនៅក្នុង ក.ក.ប.ទ/ស,ក,ប,ទ តើអ្វីជាដំណើរការ សំរាប់បន្ថែមឬ ផ្លាស់ប្តូរលក្ខន្តិកៈរបស់ ក.ក.ប.ទ/ស,ក,ប,ទ ? ច្បាប់បញ្ញត្តិរបស់ ក.ក.ប.ទ/ស,ក,ប,ទ ជាបញ្ញត្តិប្រត្តិបត្តិការជាក់ច្បាស់ សំរាប់ការអនុវត្តន៍លក្ខន្តិកៈ ក.ក.ប.ទ/ស,ក,ប,ទ ។

ខាងក្រោមនេះជាខ្លឹមសារដែលតែងតែដាក់បញ្ចូលក្នុងច្បាប់បញ្ញត្តិរបស់ ក.ក.ប.ទ/ស,ក,ប,ទ :

១ នីតិវិធីសំរាប់ទទួល និង បណ្តេញសមាជិក ។

២ តំណែង និង មុខងារដឹកនាំ ។

៣ នីតិវិធីសំរាប់ជ្រើសរើស និង ដកដំណែងមេដឹកនាំ ការកាន់កាប់ការិយាល័យ ។

៤ អធិប្បាយសំរាប់ ច្បាប់បញ្ញត្តិ បទបញ្ជាផៃក្នុង និង គោលបំណងនៃការផ្តល់ទឹក និង ថែទាំ ។

៥ ច្បាប់បញ្ញត្តិ បទបញ្ជាផ្ទៃក្នុង និង អនុម័តអំពីថ្លៃឈ្នួលសេវាកម្មប្រព័ន្ធធារាសាស្ត្រ ។

៦ រចនាសម្ព័ន្ធនៃការធ្វើសេចក្តីសំរេចចិត្តលើការសំរេចគោលនយោបាយ និង កម្មវិធី ។

៧ នីតិវិធីក្នុងការធ្វើកិច្ចសន្យា ។

៨ ពិធីការសំរាប់បង្កើតសហព័ន្ធ និង ទំនាក់ទំនងខាងក្រៅ ។

៩ នីតិវិធីសំរាប់ធ្វើវិសោធនកម្មច្បាប់បញ្ញត្តិ បទបញ្ជាផ្ទៃក្នុង ។

ក្រុម ទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ គួរចងចាំថាលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និង ច្បាប់បញ្ញត្តិ ក.ក.ប.ទ/ស,ក,ប,ទ ជាឯកសារ បំរុងជាមុន របស់មេដឹកនាំ និង សមាជិក ក.ក.ប.ទ/ស,ក,ប,ទ ។

**ជំហាន ៥: កសិករបង្កើត ក.ក.ប.ទ/ស,ក,ប,ទ និង ជ្រើសរើសមេដឹកនាំ**

៦ បោះឆ្នោតជ្រើសរើសអ្នកតំណាង ក.ក.ប.ទ/ស,ក,ប,ទ នៅកំរិតប្លុកហ៊ឺងកន្លែង ។

៧ បោះឆ្នោតជ្រើសរើសគណ:កម្មាធិការប្រឡាយទី ២ ប្រសិនបើត្រូវការ ។

៨ បោះឆ្នោតជ្រើសរើសគណ:កម្មាធិការ ក.ក.ប.ទ/ស,ក,ប,ទ ជ្រើសរើសប្រធាន និង មន្ត្រីឯទៀតនៅកំរិត ប្រព័ន្ធធារាសាស្ត្រ ។

៩ ចុះបញ្ជី ក.ក.ប.ទ/ស,ក,ប,ទ នៅក្នុងក្រសួងធនធានទឹក និង ឧតុនិយម ។

១០ ក្រសួងធនធានទឹក និង ឧតុនិយម និង ខេត្ត ទទួលស្គាល់លក្ខន្តិកៈ និង ច្បាប់បញ្ញត្តិនេះជាផ្លូវការ ។

**ជំហានទី ៦: កសាងសមត្ថភាព ក.ក.ប.ទ/ស,ក,ប,ទ ដើម្បីរៀបចំផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត**

១ បណ្តុះបណ្តាលមន្ត្រី ក.ក.ប.ទ/ស,ក,ប,ទ អំពីការផ្តល់ទឹក ការថែទាំសំណង់ រៀបផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត ការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុ ភាគច្រើនបំផុត នៃការបណ្តុះបណ្តាល គួរធ្វើការណែនាំ និង បង្ហាត់បង្រៀនលើកន្លែងការងារ ដោយក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ និង គ្រូបង្គោលដទៃទៀត។

២ ធ្វើបញ្ជីសារពើភ័ណ្ឌជាលំអិតអំពីហេដ្ឋារចនាសម្ព័ន្ធទាំងអស់ក្នុងប្រព័ន្ធធារាសាស្រ្ត និង ការវាយតំលៃលក្ខខណ្ឌដំណើរការនាពេលបច្ចុប្បន្នរបស់វា ។

៣ រួមជាមួយក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទរៀបផែនការសេវាកម្មធារាសាស្រ្តសំរាប់ស្ថានភាពបច្ចុប្បន្ននោះគឺ ថាមុនពេលជួសជុល និង កែលំអរក្នុងហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធធារាសាស្រ្ត។

៤ ដោយមានជំនួយពីក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ កំណត់គោលបំណងនៃការអភិវឌ្ឍ កសិកម្មរបស់ ក.ក.ប.ទ/ស,ក,ប,ទ។

៥ ក្នុងវិធីសាស្រ្តទូទៅ ក.ក.ប.ទ/ស,ក,ប,ទ ក៏មានតំរូវការជួសជុល និង កែលំអរហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធធារាសាស្រ្ត ដោយមានជំនួយពីក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ រៀបចំពង្រាងផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត សំរាប់ប្រមើលមើលស្ថានភាពក្រោយពេលជួសជុល និង កែលំអរក្នុង ហេដ្ឋារចនាសម្ព័ន្ធ នៃប្រព័ន្ធធារាសាស្រ្ត ដែលនឹងត្រូវធ្វើឡើងរួមមានការប៉ាន់ប្រមាណតម្លៃសំរាប់ ការអនុវត្តន៍ផែនការសេវាកម្ម ប្រព័ន្ធធារាសាស្រ្ត និង ការជួសជុលកែលំអរម្តងម្កាល។

៦ ជ្រើសរើសឬតែងតាំងបុគ្គលិកគ្រប់គ្រង ក.ក.ប.ទ/ស,ក,ប,ទ។

៧ បណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រី និង បុគ្គលិក ក.ក.ប.ទ/ស,ក,ប,ទ ក្នុងការគ្រប់គ្រងប្រព័ន្ធ ធារាសាស្រ្ត។

**ជំហានទី ៧ : ក.ក.ប.ទ/ស,ក,ប,ទ អនុម័តផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្តដំបូង**

៨ បញ្ចប់ការរៀបចំផែនការសេវាកម្ម និង ថវិកាដោយជួរគណៈកម្មាធិការ ក.ក.ប.ទ/ស,ក,ប,ទ និង អ្នកជំនួយការក្រុមទ្រទ្រង់ ក.ក.ប.ទ/ស,ក,ប,ទ។

៩ គណនាថ្លៃឈ្នួលសេវាកម្មធារាសាស្រ្ត និង កំណត់នីតិវិធីយកថ្លៃ ប្រមូល ការគ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ។ ថ្លៃឈ្នួលអាចជាប្រាក់ ជាទិន្នផល ការរួមវិភាគទានពលកម្ម ឬសំភារៈ។

១០ សិក្សា និង ព្រមព្រៀងលើផែនការសេវាកម្មប្រព័ន្ធធារាសាស្រ្ត ថវិកា និង ថ្លៃឈ្នួលកិច្ចប្រជុំរួម ក.ក.ប.ទ/ស,ក,ប,ទ។

១១ ក.ក.ប.ទ/ស,ក,ប,ទ បើកគណនីធនាគារ ឬរៀបចំទុកដាក់ និង គ្រប់គ្រងមូលនិធិដែលបាន ប្រមូល។

១២ ការប្រមូលថ្លៃឈ្នួលសេវាកម្មប្រព័ន្ធធារាសាស្រ្ត។

១៣ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស.ក.ប.ទ ជួយ ក.ក.ប.ទ/ស.ក.ប.ទ បើសិនត្រូវការ ក្នុងការអនុវត្តន៍ផែនការសេវាកម្មធារាសាស្ត្រ លើកទី១រយ:ពេល ១ ឆ្នាំសំរាប់ផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ ហើយផ្តល់ថវិកាដោយគណ:កម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ដោយមានជំនួយពីក្រុមទ្រទ្រង់ ។

**ជំហានទី ៨ : រៀបចំ និង អនុម័តកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង ឬវិញ្ញាបនប័ត្របញ្ជាក់អំណាចគ្រប់គ្រង**

១. គណ:កម្មាធិការគ្រប់គ្រង ក.ក.ប.ទ/ស.ក.ប.ទ និង ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស.ក.ប.ទ ពិភាក្សាគ្នាអំពីគំរូកិច្ចព្រមព្រៀង ការគ្រប់គ្រង ឬវិញ្ញាបនប័ត្របញ្ជាក់អំណាចគ្រប់គ្រងរបស់ ក.ក.ប.ទ/ស.ក.ប.ទ ។

២. ពង្រាងកិច្ចព្រមព្រៀងផ្ទេរត្រូវរៀបចំ ពិភាក្សា កែតំរូវនិង យល់ព្រមដោយគណ:កម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ក្រុមទ្រទ្រង់ ក.ក.ប.ទ/ស.ក.ប.ទ និង កិច្ចប្រជុំទូទៅរបស់ ក.ក.ប.ទ/ស.ក.ប.ទ ។

៣. ក្រោយពេលពេញលេញមួយឆ្នាំនៃការអនុវត្តន៍ផែនការសេវាកម្មធារាសាស្ត្រទី១ដោយជោគជ័យរួចមក កិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង ឬវិញ្ញាបនប័ត្របញ្ជាក់ការគ្រប់គ្រងរបស់ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវចុះហត្ថលេខាដោយគណ:កម្មាធិការគ្រប់គ្រង ក.ក.ប.ទ/ស.ក.ប.ទ និង ក្រសួងធនធានទឹក និង ឧតុនិយម ។ នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធធារាសាស្ត្រភាគច្រើនកំពុងត្រូវបានគ្រប់គ្រងដោយកសិករ និង អាជ្ញាធរ មូលដ្ឋាន។ ដូច្នេះកិច្ចព្រមព្រៀង ផ្ទេរការគ្រប់គ្រងរបស់ ក.ក.ប.ទ/ស.ក.ប.ទ មានប្រយោជន៍ណាស់ដើម្បីបំភ្លឺ និង ឱ្យមតិសាធារណ:ទទួលស្គាល់ជាផ្លូវការថា ក.ក.ប.ទ/ស.ក.ប.ទ មានការទទួលខុសត្រូវ និង អំណាចក្នុងការត្រួតពិនិត្យការគ្រប់គ្រងសំណង់ប្រព័ន្ធធារាសាស្ត្រ។ កិច្ចព្រមព្រៀងផ្ទេរឬវិញ្ញាបនប័ត្រ បញ្ជាក់អំពីការបែងចែកសិទ្ធិ ការទទួលខុសត្រូវកាតព្វកិច្ច និង អំណាចនាពេលអនាគតរវាង ក.ក.ប.ទ/ស.ក.ប.ទ និង រដ្ឋាភិបាល ។

**ខាងក្រោមនេះគឺជាខ្លឹមសារនៃកិច្ចព្រមព្រៀងផ្ទេរការគ្រប់គ្រង:**

១ តំបន់សេវាកម្ម និង លក្ខណ:វិនិច្ឆ័យសមាជិកភាពរបស់ ក.ក.ប.ទ/ស.ក.ប.ទ។

២ ធ្វើបញ្ជីសារពើភ័ណ្ឌនៃហេដ្ឋារចនាសម្ព័ន្ធ និង សំភារ:តាមកាល:ទេស:ប្រសិនបើមាន ហើយបំភ្លឺ អំពីកម្មសិទ្ធិភាព ឬសិទ្ធិប្រើប្រាស់រយ:ពេលវែងក្នុងរចនាសម្ព័ន្ធដែលត្រូវផ្ទេរឱ្យក.ក.ប.ទ/ស.ក.ប.ទ។

៣ សិទ្ធិជាមូលដ្ឋានអំណាច និង កាតព្វកិច្ចរបស់ ក.ក.ប.ទ/ស.ក.ប.ទ។

៤ សិទ្ធិ និង អំណាច និង កាតព្វកិច្ចរបស់រដ្ឋាភិបាលចំពោះ ក.ក.ប.ទ/ស.ក.ប.ទ ដូចជាត្រូវធ្វើនិយ័តកម្ម កសាងសមត្ថភាព និង ផ្តល់សេវាកម្មគាំទ្រ។

៥ នីតិវិធីសំរាប់ដោះស្រាយជម្លោះ។

៦ គោលបំណង និង ខ្លឹមសារនៃផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ និង កាតព្វដើម្បីរៀបចំ។

៧ គោលបំណងនីតិវិធី និង សារៈសំខាន់នៃសេវាកម្មការគ្រប់គ្រងធារាសាស្ត្រ។

៨ ពិធីការសំរាប់ទំនាក់ទំនងរវាង ក.ក.ប.ទ/ស.ក.ប.ទ និង រដ្ឋាភិបាល។

៩ អាណត្តិ និង លក្ខខណ្ឌសំរាប់ការផ្ទេរដែលត្រូវសើរើឡើងវិញ។

១០ នីតិវិធីសំរាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងផ្ទេរ។

# ផ្នែកទី ២. កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ

## ១- លក្ខណៈទូទៅនៃប្រពន្ធ័ធារាសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយដែលស្ថិតនៅតំបន់ត្រូពិក ក្តៅហើយសើម ហើយចែកចេញជាពីររដូវគឺៈ

- រដូវប្រាំង ចាប់ផ្តើមពីខែវិច្ឆកា ទៅដល់ ខែមេសា ( ខែ១១ ដល់ ខែ០៤ )
- រដូវវស្សា ចាប់ផ្តើមពីខែឧសភា ទៅដល់ ខែតុលា ( ខែ០៥ ដល់ ខែ១០ )

ប្រទេសកម្ពុជាមានផ្ទៃដី 181,035គម$^2$ ដែលក្នុងនោះមាន១/៣នៃផ្ទៃដីសរុបដែលជាដីសំរាប់ដំណាំកសិកម្ម លើសពីនេះទៅទៀត ប្រទេសកម្ពុជាមានប្រជាជនប្រមាណជា 80% ជាអ្នកប្រកបរបរកសិកម្ម។ ដូច្នេះកត្តាសំខាន់សំរាប់ប្រទេសកសិកម្មគឺទឹកព្រោះទឹកនេះហើយដែលជាដង្ហើមរស់របស់មនុស្ស សត្វ និងរុក្ខជាតិ ដូចជាពោត សណ្តែកដំឡូង ល្ង កៅស៊ូ កប្បាស ជាពិសេសគឺដំណាំស្រូវនេះតែម្តង។ ដូចនេះដើម្បីអោយការបង្កបង្កើនផល ដំណើរការបានគ្រប់រដូវនៅទូទាំងប្រទេស យើងចាំបាច់ត្រូវតែធ្វើការស្តាបនាប្រពន្ធ័ធារាសាស្ត្រអោយបានគ្រប់គ្រាន់ ដើម្បីធានាបានក្នុងការស្រោចស្រពដំណាំឱ្យទទួលបានទិន្នផលខ្ពស់។

ដើម្បីអោយប្រពន្ធ័ធារាសាស្ត្រ ដំណើការទៅបានល្អនោះ ទាមទាអោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងនោះ រួមទាំងប្រជាកសិករផងដែរ ( បង្កើត ក.ក.ប.ទ/ស.ក.ប.ទ )។

ដោយផ្អែកទៅលើហេតុផលទាំងឡាយខាងលើនេះទើបក្រសួងធនធានទឹក និង ឧតុនិយម បានរៀបចំចាត់ចែងអោយមានវគ្គបណ្តុះបណ្តាលប្រពន្ធ័ធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ ដែលមានរយៈពេលខ្លីនេះឡើងដើម្បីផ្លាស់ប្តូរបទពិសោធន៍រវាងគ្នានឹងគ្នាទៅវិញទៅមកក្នុងគោលបំណងរួមចំណែកស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិអោយបានឿនលឿនឈានទៅរកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដូចបណ្តាប្រទេសនៅលើពិភពលោក។ ប្រព័ន្ធធារាសាស្ត្រគឺជាបណ្តុំនៃសំណង់ទាំងឡាយដែលបំរើអោយការងារស្រោចស្រពនិងបញ្ចៀសនូវការលិចលង់ផ្សេងៗ ប៉ុន្តែមិនមែនមានន័យថា សំណង់នេះអាចបំរើតែការងារស្រោចស្រពប៉ុណ្ណោះទេ វាមានតួនាទីផ្សេងៗតាមតម្រូវការដែលយើងចង់បាន ។

## ២- អត្ថប្រយោជន៍នៃប្រពន្ធ័ធារាសាស្ត្រ

- ផ្តល់ទឹកដើម្បីបបង្កបង្កើនផលដំណាំផ្សេងៗ( ពិសេសដំណាំស្រូវ )។
- ធ្វើឱ្យកសិករទទួលបាននូវទិន្នផលខ្ពស់តាមរយៈការប្រើប្រាស់បច្ចេកទេសដាំដុះទំនើប។
- កសិករអាចបង្កបង្កើនផលបានពីរដងក្នុងមួយរដូវដោយគ្រាន់តែដាំដំណាំឆ្លាស់មុខ ( ស្រូវ-ឪឡឹក )។
- ធានាបាននូវសុវត្ថិភាពស្បៀង សំរាប់កសិករ ( កសិករមានជីវភាពធូរធារ ) ។
- កសិករមានឱកាសសំរាប់ធ្វើការអភិវឌ្ឍន៍គំរោងផ្សេងៗទៀត ( ពង្រីកប្រពន្ធ័ធារាសាស្ត្រ )។

## ៣ - បញ្ហារួមចំពោះប្រព័ន្ធធារាសាស្ត្រ

ចំពោះប្រព័ន្ធធារាសាស្ត្រ ដែលមានបញ្ហាកើតឡើងជាញឹកញយ គឺបណ្តាលមកពីការងារគ្រប់គ្រងបច្ចេកទេស និង គ្រោះមហន្តរាយ ។

### ៣.១ ការគ្រប់គ្រង

ការគ្រប់គ្រង ជាបញ្ហាមួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ការប្រើប្រាស់ទឹកដែលមិនមានកាលវិភាគច្បាស់លាស់ គ្មានក្រុមកសិករប្រើប្រាស់ទឹក មានការកាប់ភ្លឺប្រឡាយយកទឹក ឬធ្វើទំនប់ក្នុងប្រឡាយ ដែលខ្វះការទទួលខុសត្រូវ និង ការចូលរួមថែទាំពីកសិករ ។ ឧទាហរណ៍ៈ រូបភាពបង្ហាញខាងក្រោម គឺនៅតំបន់គំរូក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល


កាប់ភ្លឺប្រឡាយបង្ហូរទឹក


ធ្វើទំនប់ក្នុងប្រឡាយ

### ៣.២- ការងារបច្ចេកទេស

បញ្ហារួមលើការងារបច្ចេកទេស គឺអ្នកបច្ចេកទេស (អ្នកគ្រោងប្លង់) មិនបានធ្វើការសិក្សាឱ្យលំអិតពីបរិមាណធារទឹកអោយបានច្បាស់លាស់មុនពេលគ្រោងប្លង់ អ្នកគ្រោងប្លង់មិនបានដឹងពីកំរិតលំហូរទឹកដែលមាននៅក្នុងអាង។ ការខ្វះខាតទឹកតាមរយៈការបាត់បង់ដោយរំហួត ជំរាប និងការបាត់បង់តាមប្រពន្ធ័ធារាសាស្ត្រទាំងមូល ។

### ៣.៣- គ្រោះមហន្តរាយ

ភាគច្រើននៃប្រពន្ធ័ធារាសាស្ត្រត្រូវទទួលរងគ្រោះដោយធម្មជាតិ និងមនុស្សជាអ្នកបង្កឡើងតាមរូបភាព ផ្សេងៗ ការហូរច្រោះពីទឹកភ្លៀងឬគំរាមកំហែងពីទឹកជំនន់រៀងរាល់ឆ្នាំបណ្តាលឱ្យទំនប់ ប្រឡាយ សំណង់ត្រូវហូរ ច្រោះដាច់ និង ស្រុតសំណង់ ការជីកអន្លុងក្នុងប្រឡាយចាប់ត្រី ការកាប់ភ្លឺប្រលាយបង្ហូរទឹកមិនដាក់លូ។ ការបើកទ្វារទឹកដាក់ទ្រូចាប់ត្រីតាមសំណង់ធារាសាស្ត្រ បណ្តាលអោយទំនប់ប្រលាយ និងសំណង់ត្រូវហូរច្រោះដាច់។

ឧទាហរណ៍ៈ រូបភាពបង្ហាញពីប្រព័ន្ធធារាសាស្ត្រដែលរងគ្រោះនៅតំបន់គំរូ ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល





ប្រព័ន្ធស្រោចស្រពរងគ្រោះដោយទឹកជំនន់ ( ហូរច្រោះដាច់ខ្នង ប្រលាយ )




*ប្រព័ន្ធធារាសាស្ត្ររងគ្រោះដោយសារមនុស្សកាប់ភ្លឺប្រលាយបង្ហូរទឹកចូលស្រែ*




*ប្រព័ន្ធធារាសាស្ត្ររងគ្រោះដោយការជីកធ្វើអន្លង់ត្រីក្នុងប្រលាយ*

កត្តាទាំងនេះស្ទើរតែកើតឡើងគ្រប់ប្រពន្ធ័ធារាសាស្ត្រទាំងអស់។ ដើម្បីដោះស្រាយបញ្ហានេះមានតែក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក និង សមាជិកសហការណ៏គ្នាដោះស្រាយទើបមានប្រសិទ្ធិភាព។

## ៤- ប្រភពទឹកស្រោចស្រព

ប្រភពទឹកដែលត្រូវការសំរាប់ប្រើប្រាស់ស្រោចស្រពដំណាំមានពសំខាន់គឺ ទឹកភ្លៀង ទឹកលើដីមាន (ទន្លេ ព្រែក ស្ទឹង បឹងជាដើម) និងប្រភពទឹកក្រោមដី។ ក្នុងចំណោមប្រភពទឹកទាំងពខាងលើនេះ យើងឃើញថា ប្រភពទឹកលើដីមានលក្ខណ:ងាយស្រួលជាងគេ ដើម្បីទាញយកទឹកមកស្រោចស្រពលើដំណាំផ្សេងៗ។

## ៥- ប្រភេទប្រព័ន្ធធារាសាស្ត្រ

### ៥.១- ទំហំខ្នាតនៃប្រពន្ធ័ធារាសាស្ត្រ

ប្រពន្ធ័ធារាសាស្ត្រត្រូវបានបែងចែកទៅតាមទំហំផ្ទៃដីប្រើប្រាស់ទឹកដែលកំណត់ដោយក្រសួងធនធានទឹក និងឧតុនិយម ដែលមានចែងដូចខាងក្រោម :

- ខ្នាតតូច - គឺប្រពន្ធ័ធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីមិនលើលពី ២០០ ហិកតា

- ខ្នាតមធ្យម - គឺប្រពន្ធ័ធារាសាស្ត្រដែលអាចស្រោចស្រពលើផ្ទៃដីចាប់ពី ២០០ ហិកតា ទៅ ៥០០០ ហិកតា
- ខ្នាតធំ - គឺប្រពន្ធ័ស្រោចស្រព ដែលអាចស្រោចស្រពលើផ្ទៃដី ចាប់ពី ៥០០០ ហិកតា ឡើងទៅ

### ៥.២- និរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ

- ត្រូវមានការចូលរួមពីកសិករ ( រៀបចំក្រុម/សហគមន៍កសិករប្រើប្រាស់ទឹក )
- ប្រភពទឹកគ្រប់គ្រាន់សំរាប់ស្រោចស្រព
- ការកែលំអរដីធ្លីធ្វើឱ្យមានជីជាតិ
- ថវិការសំរាប់ជួសជុល និង ថែទាំប្រចាំឆ្នាំ
- បើកវគ្គបណ្តុះបណ្តាលដល់កសិករពីកិច្ចដំណើរការគ្រប់គ្រង និង ការថែទាំប្រព័ន្ធ
- ការគាំទ្រពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និង ក្រសួងស្ថាប័នពាក់ពន្ធ័

### ៥.៣- មុខងារ និង សារៈប្រយោជន៏នៃសំណង់នីមួយៗ

#### ៥.៣.១- មុខងារនៃប្រព័ន្ធប្រឡាយ

ប្រព័ន្ធប្រឡាយត្រូវបានគេទទួលស្គាល់ថាជាបណ្តាញដែលនាំទឹកពីប្រភពទឹកទៅកន្លែងស្រោចស្រព ហើយប្រព័ន្ធនេះបានបង្កើតឡើងនូវប្រឡាយជាច្រើនខ្សែ ។

- **ប្រលាយមេ (MC)** ជាប្រឡាយនាំទឹកពីអាង រឺពីប្រភពទឹកចូលក្នុងប្រឡាយប្រលាយរងទី១ (SC)




- **ប្រឡាយរងទី១** (SC) ជាប្រឡាយនាំទឹកពីប្រឡាយមេទៅប្រឡាយរងទី២ ‘Tertiary Canal”




- **ប្រឡាយរងទី២ (Tertiary Canal)** ជាប្រឡាយនាំទឹកពីប្រឡាយរងទី១ទៅប្រលាយជើងក្អែប




- **ប្រឡាយជើងក្អែប៖** ជាប្រឡាយដែលនាំទឹកពីប្រឡាយរងទី២ ទៅកាន់តំបន់ស្រោចស្រព និងដីស្រែ ។




ប្រឡាយជើងក្អែប កណ្ដាលស្ទឹង

- **ប្រឡាយដោះទឹកមេ (MD)** : គឺជាប្រឡាយដោះទឹក ដែលទទួលទឹកពីប្រឡាយដោះទឹករងទី១ និងប្រលាយដោះទឹក ប្លុក ។
- **ប្រឡាយដោះទឹករងទី១ (SD)** : គឺជាប្រឡាយដោះទឹក ដែលទទួលទឹកពីប្រឡាយដោះទឹករងទី២ហើយ នាំទឹកទាំងនោះទៅកាន់ប្រលាយដោះទឹករងទី១ ។
- **ប្រឡាយដោះទឹករងទី២(TD):** គឺជាប្រឡាយដោះទឹកដែលមានស្ថានភាពជ្រៅជាងប្រឡាយរងស្រោចស្រព ហើយមុខងាររបស់វាគឺទទួលទឹកពីប្រឡាយដោះទឹករងទី២‘TertiaryDrain” រឺ ដីស្រែហើយនាំទឹក ទាំងនោះ ទៅកាន់ប្រឡាយ ដោះទឹករងទី១ ។

ប្រឡាយដោះទឹក




## ៥,៤- មុខងារនៃសំណង់សិល្បៈការ

**- សំណង់ក្បាលហុង (Intake structure):**

ជាសំណង់សំរាប់បញ្ចេញទឹកពីអាងរ៉ី ពីប្រភពទឹក ចូលក្នុង ប្រឡាយមេតាមរយៈទ្វារទឹក ។



សំណង់មេកណ្តាលស្ទឹង



សំណង់ក្បាលហុងកណ្តាលស្ទឹង

**- សំណង់នាំទឹក ទៅប្រលាយរងទី១ (Turnout):**

មាននៅដើមប្រលាយរង (SC) សំរាប់នាំទឹកពីប្រលាយមេ ទៅបញ្ចូលទៅប្រលាយរងទី១ ។



ខាងមុខសំណង់



ខាងក្រោយសំណង់

- **សំណង់ស្ទាក់ទឹក :** សំរាប់បញ្ចូលទឹកក្នុងប្រឡាយរង ចូលទៅក្នុងប្រលាយស្រោចស្រពប្លុក។





- **សំណង់លូមូល និងលូប្រអប់**

ជាសំណង់សំរាប់មនុស្ស សត្វ និងយានជំនិះផ្សេងៗឆ្លងកាត់ពីខ្នងប្រលាយម្ខាងទៅម្ខាងទៀត។ សំណង់នេះ ត្រូវបានគេសាងសង់នៅត្រង់ចំណុចដែលប្រលាយពីរកាត់គ្នា តួនាទីរបស់វាសំរាប់ស្ទាក់ទឹក បង្កើនកំរិតកំពស់ទឹក និងបង្វែរទឹកទៅប្រឡាយផ្សេងទៀត។





- **សំណង់បញ្ចូលទឹក (Outlet)**

មាននៅដើមប្រលាយស្រោចស្រពប្លុក**ប្រឡាយរងទី២** (Tertiary Canal) សំរាប់នាំទឹកពីប្រលាយរងទី២ ទៅប្រលាយជើងក្អែប (Delivery Canal) ។



ខាងមុខសំណង់



ខាងក្រោយសំណង់

**- បំពង់បញ្ចូលទឹក (Pipe outlet)**

មាននៅតាមប្រឡាយរងទី២និងទី៣ "Tertiary Canal and delivery canal" ហើយវាមានតួនាទីនាំទឹកចេញពីប្រលាយរងទាំងនោះចូលទៅក្នុងស្រែដោយផ្ទាល់តែម្តង ។





**- សំណង់ស៊ីហ្វុង (Siphon Structure) :** ជាប្រភេទសំណង់សំរាប់ចំលងទឹកពីតំបន់មួយទៅតំបន់មួយទៀត ដោយមានប្រឡាយកាត់គ្នា ។

**- សំណង់ស្ពាក់ទឹកចុងប្រឡាយ (Tail Escape Structure):** ជាប្រភេទសំណង់សំរាប់បញ្ចាល់ទឹក ដើម្បីអោយកំពស់ទឹកក្នុងប្រឡាយមានស្ថេរភាពងាយស្រួលហូរចូលប្រព័ន្ធស្រោចស្រព និងសំរាប់ដោះទឹកចេញពីប្រឡាយស្រោចស្រព នៅពេលទឹកលើសពីតម្រូវការស្រោចស្រព ។



# ផ្នែកទី ៣៖ ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

## ១. សេចក្តីផ្តើម

ប្រពន្ធ័ប្រឡាយនាំទឹកក្នុង ក្រុម/សហគមន៍ គឺជាប្រពន្ធ័ធារាសាស្ត្រដែលសង្កត់ធ្ងន់ទៅលើការប្រើប្រាស់ទឹក ដើម្បីផ្គត់ផ្គង់ និង ចែកចាយទឹកដល់ការដាំដុះ។ ដើម្បីប្រើប្រាស់ទឹកអោយបានសមស្រប ឬក៏មិនមានឥទ្ធិពលដល់លក្ខខ័ណ្ឌបច្ចេកទេស ធម្មជាតិ ដាំដុះ និងគុណភាពដី។ កិច្ចការគ្រប់គ្រងប្រពន្ធ័ធារាសាស្ត្រមានសារៈសំខាន់ណាស់នៅក្នុងតំបន់ស្រោចស្រព។ គេចែកការងារគ្រប់គ្រងជា២ផ្នែកក្នុងប្រពន្ធ័ធារាសាស្ត្រ គឺការគ្រប់គ្រងសំណង់ធារាសាស្ត្រ និង ការគ្រប់គ្រងទឹកស្រោចស្រព។

## ២. ការគ្រប់គ្រងសំណង់ធារាសាស្ត្រ

ការគ្រប់គ្រងសំណង់ធារាសាស្ត្រគឺមានភារកិច្ចយ៉ាងសំខាន់ និងដោយផ្ទាល់ក្នុងការចែកចាយ និងនាំយកទឹកក្នុងប្រពន្ធ័ទៅកាន់វាលស្រែ។ ប្រពន្ធ័ប្រឡាយស្រោចស្រព និងដោះទឹកមិនបានថែទាំល្អ បណ្តាលអោយសំណង់ទាំងនោះមិនដំណើរការ ទោះបីជាការសាងសង់សំណង់ទាំងនោះមានលក្ខណៈត្រឹមត្រូវ និងសមស្របក៏ដោយ ក៏ការទទួលមកវិញមិនបានលទ្ធផលល្អដែរ។ ការគ្រប់គ្រងសំណង់ធារាសាស្ត្រមានចំណុចសំខាន់ដូចខាងក្រោម៖

- ការគ្រប់គ្រងសំណង់ក្នុងប្រព័ន្ធទាំងមូល សំដៅលើការប្រើប្រាស់សំណង់ប្រកបដោយប្រសិទ្ធិភាពតាមបច្ចេកទេសយ៉ាងត្រឹមត្រូវ ធានាការចែកចាយនាំទឹកទៅតំបន់ស្រោចស្រព និង កាត់បន្ថយភាពខូចខាត ។
- សិក្សាស្វែងរកនូវការកាត់បន្ថយភាពខ្ជះខ្ជាយដូចជា ជំរាប និងលើកកំពស់សក្តានុពលភាពនៃទឹកអោយកាន់តែទូលាយលើផ្ទៃដីស្រោចស្រោព ដែលសមស្របទៅនឹងសេចក្តីត្រូវការដាំដុះ ។
- សិក្សាស្វែងរកនូវរបៀបដែលទប់ស្កាត់ការច្រោះដាច់ ឬការងាររបស់ប្រឡាយនាំទឹកដើម្បីកាត់បន្ថយការងារជួសជុល និង ធានាដល់ការនាំទឹករបស់ប្រឡាយ ។
- សិក្សាស្វែងរកបន្ថែមក្នុងការកែប្រែប្រពន្ធ័ដើម្បីបំពេញសេចក្តីត្រូវការបច្ចេកទេសស្រោចស្រព ដោយស្វ័យប្រវត្តិ។

## ៣. ការគ្រប់គ្រងទឹកសំរាប់ស្រោចស្រព

### ៣.១- និយមន័យ

ការគ្រប់គ្រងទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រគឺមានសារៈសំខាន់ដើម្បីអោយប្រព័ន្ធប្រើប្រាស់បានយូរអង្វែង និងដឹងពីតម្រូវការទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រ និងប្រឡាយចែកចាយ ដែលមាននៅក្នុងតំបន់នោះ។ តម្រូវការត្រួតពិនិត្យយ៉ាងត្រឹមត្រូវនៅពេលដែលធារទឹកនៅក្នុងអាងឬប្រឡាយកើនឡើងជាមួយនឹងកំរិតកំពស់ទឹកដែលវានឹងមានគ្រោះថ្នាក់ទៅលើខ្នងទំនប់ ឬប្រឡាយដែលទឹកហូរច្រោះពីលើ។ ដូច្នេះដើម្បីជៀសវាងកុំអោយទឹកហូរច្រោះលើខ្នងទំនប់ឬប្រឡាយ គឺធ្វើយ៉ាងណាកុំអោយទឹកលើសពីកំពស់សុវត្ថិភាព ហើយបើលើសត្រូវបង្ហូរវាចេញ ពេលនោះត្រូវជូនដំណឹងដល់អ្នកដែលរស់នៅខាងក្រោមអោយបានដឹងជាមុនជៀសវាងគ្រោះថ្នាក់ណាមួយកើតមានឡើង។

### ៣.២- គោលបំណងនៃការគ្រប់គ្រងទឹកៈ

ដើម្បីផ្គត់ផ្គង់ និងចែកចាយទឹកទៅដល់ការដាំដុះនិងជៀសវាងការខ្វះខាតទឹក យើងត្រូវដឹងពីបរិមាណធារទឹកនៅក្នុងប្រព័ន្ធស្រោចស្រពអោយបានច្បាស់លាស់។

### ៣.៣- កិរិតនៃការគ្រប់គ្រងទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រ

- **ការគ្រប់គ្រងអាងស្តុបទឹក រឺស្ទឹង**

ការគ្រប់គ្រងទឹកនៅអាងស្តុបទឹកស្ទឹងគឺជាការគ្រប់គ្រងយ៉ាងសំខាន់ ពីព្រោះទឹកភ្លៀងនៅលើតំបន់ភ្នំ ផ្នែកខាងលើនៃស្ទឹង បានហូរកាត់តាមកូនស្ទឹងតូចៗជាច្រើនចូលមកក្នុងស្ទឹង។ អាងទឹក រឺ ស្ទឹង មានតួនាទីសំរាប់តំកល់ទឹកទុកនៅក្នុងអាងទឹក ដោយសំណង់បង្ហៀរស្ទាក់ទឹកសំរាប់តំកល់ទឹកទុកបម្រើលើការងារស្រោចស្រព និងបញ្ចេញទឹកដែលលើសពីកំពស់សុវត្ថិភាពរបស់អាងចេញតាមស្ទឹងចុះទៅក្រោម។ ការបង្ហូរទឹកពីស្ទឹងត្រូវបានបង្ហូរទៅផ្នែកខាងក្រោមតាមទ្វារទឹកនឹងសំណង់បង្ហៀរដើម្បីបែងចែកឱ្យកសិកររស់នៅផ្នែកខាងក្រោមប្រើប្រាស់ និង ស្រោចស្រពដំណាំស្រូវទៅតាមតម្រូវការ។ ទ្វារទឹកត្រូវបានបិទ រឺ បើកចាប់ពីដើមរដូវ នៅខែឧសភា រហូតដល់ខែធ្នូ ជារៀងរាល់ឆ្នាំ អាស្រ័យទៅលើស្ថានភាពទឹកនៅក្នុងស្ទឹង។ ប៉ុន្តែនៅចន្លោះខែឧសភា និងខែកញ្ញា អាចមានទឹកជំនន់កើតឡើង ហើយទ្វារទឹកត្រូវបានបើកដោយភ្នាក់ងារធនធានទឹកស្រុក ដើម្បីជួយដោះទឹកបន្ថែមពីសំណង់បង្ហៀរកុំអោយខូចខាតសំណង់ និង ការពារកុំអោយលិចលង់ផលដំណាំ និងស្រូវរបស់កសិករនៅផ្នែកខាងលើ។ ទ្វារទឹកនៅសំណង់ស្ទាក់ទឹកស្ទឹង នឹង បិទវិញនៅពេលដែលទឹកស្រកដល់កំរិតសុវត្ថភាព គឺស្មើនឹងខ្នងសំណង់បង្ហៀរ (Crest of Spillway Structure)។

- **ការគ្រប់គ្រងប្រឡាយមេ**

យើងត្រូវរៀបចំផែនការប្រើប្រាស់ទឹក គឺសំដៅលើការប្រើប្រាស់ ការបែងចែក ការលើកកំពស់សមត្ថភាពស្រោចស្រពរបស់ប្រឡាយ អោយសមស្របបំផុត និងធានាដល់តម្រូវការទឹករបស់ដំណាំ។ យើងត្រូវដឹងចំនួនផ្ទៃដីស្រែដែលត្រូវការទឹក ងាយស្រួលផ្តល់ទឹកអោយទាន់ពេលវេលា។ កាលណាយើងមានផែនការស្រោចស្រពច្បាស់លាស់ យើងនឹងជៀសវាងការលិចលង់និងខ្វះទឹកស្រោចស្រពលើវាលស្រែ។ យើងត្រូវមានអ្នកត្រួតពិនិត្យប្រព័ន្ធប្រឡាយ និង ទ្វារទឹកលើកិច្ចដំណើរការ ការថែទាំប្រឡាយ និងសំណង់សំណង់សិល្បៈការនានា។

- **ការគ្រប់គ្រងទឹកនៅតាមប្រលាយរង**

តម្រូវអោយកសិករមានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍សំណង់ធារាសាស្ត្រ យល់ដឹងពីតម្រូវការទឹករបស់ស្រែនិមួយៗ ប្រឡាយរងនិមួយៗ បែបនេះគឺងាយស្រួលក្នុងការបែងចែកទឹក។ ត្រូវយល់ដឹងពីកំរិតកំពស់ទឹកអតិបរិមាទឹកនៅក្នុងប្រឡាយកុំអោយទឹកហូរលើខ្នងប្រឡាយនាំអោយខូចប្រឡាយ ត្រូវយល់ដឹងពីការបិទបើកទ្វារទឹកធ្វើយ៉ាងណាអោយបានសមស្រប។ ចំពោះការថែទាំយើងត្រូវចូលរួមថែទាំប្រឡាយ សំណង់ ការពារការបើកទឹកគ្មានការអនុញ្ញាត្តិ សត្វដើរលើភ្លឺប្រឡាយ និង ការរាំងស្ទះក្នុងប្រឡាយដោយប្រការមិនចាំបាច់ផ្សេងៗ។

- **ការគ្រប់គ្រងទឹកទឹកតាមប្រឡាយស្រោចស្រពៈ**

នៅពេលដែលកំរិតកំពស់ទឹកនៅក្បាលហុង (Intake) ឡើងដល់កំរិតកំពស់គ្រោងនោះ ទ្វារទឹកនៅដើមប្រឡាយមេត្រូវបើកដើម្បីទឹកហូរចូលក្នុងប្រឡាយមេ ហើយបែងចែកទៅប្រឡាយស្រោចស្រពរងទី១ រួចចូលទៅក្នុងប្រលាយស្រោចស្រពប្លុកទី២ (Tertiary Canal) ហើយចូលទៅក្នុងប្រលាយជើងក្អែប និងចូលស្រែ ក្នុងនៃប្រព័ន្ធស្រោចស្រព ។ផែនការប្រើប្រាស់ទឹកក្នុង ក្រុម/សហគមន៍ គឺជាមូលដ្ឋានគ្រឹះដើម្បីបំពេញអោយបានគ្រប់គ្រាន់នូវតំរូវការប្រើប្រាស់ទឹករបស់បណ្តារុក្ខជាតិតាមរបៀបស្រោចស្រពដែលបានកំណត់ ។ ការកសាងផែនការស្រោចស្រពមិនបានល្អ នោះ នឹងមានឥទ្ធិពលអាក្រក់ដល់កិច្ចការប្រើប្រាស់ទឹក ។ ដូចនេះដើម្បីកសាងផែនការប្រើប្រាស់ទឹកត្រូវមានៈ

- ផែនការដាំដុះតាមរដូវក្នុងតំបន់មានផ្ទៃដី.ទិន្នផល និង ពូជ
- បច្ចេកទេសដាំដុះនៃបណ្តុលរុក្ខជាតិ កាប់ឆ្ការ ដាស់ដី ភ្ជួររាស់ ប្រមូលផល
- ទិន្នន័យតម្រូវការស្រោចស្រព និងបច្ចេកទេសស្រោចស្រពដល់បណ្តុលប្រភេទដំណាំ ។
- ធារទឹក មេគុណបាត់បង់ធារទឹក និងសមត្ថភាពបែងចែកទឹករបស់បណ្តុលប្រឡាយនិងសំណង់ក្នុងប្រព័ន្ធធារាសាស្ត្រ ។

### ៣.៤ ការកំណត់តម្រូវការទឹកស្រោចស្រពលើប្រភេទដំណាំ

**ក.តំរូវការនៃដំណាំ :**

១. ជាទូទៅដូចជាមនុស្សដែរ ដំណាំទាំងអស់ ត្រូវការសមាសធាតុច្រើនយ៉ាងដើម្បីទ្រទ្រង់ជីវិតរស់នៅ និងការលូតលាស់ក្នុងន័យនេះតំរូវការចាំបាច់សំរាប់រុក្ខជាតិមាន ដី ទឹក ខ្យល់ និងពន្លឺព្រះអាទិត្យដែល :

- ដីផ្តល់ស្ថេរភាពដល់ដំណាំវាផ្ទុកទឹក និងផ្តល់សារធាតុចិញ្ចឹមដល់ដំណាំ ដែលស្រូបយកតាមរយៈឫសរបស់វា ។
- ពន្លឺព្រះអាទិត្យផ្តល់ថាមពលដែលចាំបាច់សំរាប់ការលូតលាស់
- ខ្យល់អាកាស ផ្តល់ដល់ដំណាំនូវការដកដង្ហើម
- ទឹកជាកត្តាចំបងបំផុតសំរាប់ការរស់រាននៃរុក្ខជាតិ ប៉ុន្តែទឹកច្រើនពេកក៏មិនល្អសំរាប់ដំណាំមួយចំនួនផងដែរ ។

២. តំណាក់កាលលូតលាស់របស់ដំណាំមានបួនដំណាក់កាល :

- តំណាក់កាលដំបូង គឺជាខណ:ពេលបណ្តុះកូនរី សាបព្រោះ
- តំណាក់កាលលូតលាស់ គិតចាប់តាំងពីថ្ងៃដាំរី ស្ទូងរហូតដល់ដំណាំមានផ្កា
- តំណាក់កាលដាក់ផ្លែរី ពាក់កណ្តាលរដូវ
- តំណាក់កាលចុងក្រោយ ចាប់ពីស្រូវទុំរហូតច្រូតកាត់

៣. ទឹកស្រោចស្រព មានទឹកភ្លៀង និងទឹកដែលរក្សាទុកក្នុងអាងស្តុកទឹក ( រឺ អាចទឹកក្រោមដី )

**៣.១ - តំរូវការទឹកសំរាប់ដំណាំ :**

-ដើម្បីដឹងពីតំរូវការទឹកសំរាប់ស្រោចស្រពសរុប ត្រូវដឹងពីរយៈពេលដាំដុះសរុបតាមប្រភេទដំណាំ និង តាមដំណាក់កាលលូតលាស់និមួយៗរបស់ ។

- តំរូវការទឹករបស់ដំណាំ រួមមានការជ្រាប និងរំហួត (រំហួតតាមរុក្ខ និងរំភាយតាមបរិយាកាស) (ET crop) ហើយដែលត្រូវបានកំណត់ជាជំរៅ រឺ បរិមាណដែលត្រូវឆ្លើយតបទៅនិងការបាត់បង់ តាមរយៈ រំហួត និងជ្រាប ដែលជាទូទៅបានបង្ហាញជា ម.ម/ថ្ងៃ,ខែ,រដូវ




រូប១-រំហួតរុក្ខរំភាយ (ការជ្រាប និងរំហួត)




រូប២-តំរូវការទឹករបស់តំណាំ១០ម.ម/ថ្ងៃ

**៣.២- កត្តាដែលមានឥទ្ធិពលចំពោះតំរូវការទឹកលើដំណាំ**

- អាកាសធាតុដែលក្តៅ ត្រូវការទឹកច្រើនជាងត្រជាក់
- ប្រភេទដំណាំ : ដូចជាស្រូវត្រូវការទឹកច្រើនជាងដំណាំផ្សេងទៀត
- ប្រភេទដំណាំជាកត្តាដែលជះឥទ្ធិពលលើដំណាំជារៀងរាល់ថ្ងៃ ដែលមានន័យថា ស្រូវដែលដុះរួចហើយវាត្រូវការទឹកច្រើនជាងពោត
- រយៈពេលដាំដុះនៃដំណាំៈ តំរូវការទឹកប្រចាំថ្ងៃស្រូវច្រើនជាងដំណាំអំពៅ តែតំរូវការទឹកប្រចាំរដូវរបស់អំពៅច្រើនជាងស្រូវដោយមានរយៈពេលវែងជាងស្រូវ

**៣.៣- ឥទ្ធិពលអាកាសធាតុចំពោះតំរូវការទឹក**

ឥទ្ធិពលអាកាសធាតុលើតំរូវការទឹករបស់ដំណាំគឺ រំហួត និងជំរាបយោងរបស់ដំណាំ ETo ដែលគិតជា មម/ថ្ងៃ , មម/ខែ , មម/រដូវ ។

# ផ្នែកទី ៤. កិច្ចដំណើរការប្រព័ន្ធធារាសាស្ត្រ

## ១. កិច្ចដំណើរការប្រពន្ធ័ធារាសាស្ត្រ

កិច្ចដំណើរការនៃប្រពន្ធ័ធារាសាស្ត្រ គឺជាការផ្តល់បរិមាណទឹកដល់កសិករនៅក្នុងរយះពេលមួយត្រឹមត្រូវ។ ចំពោះប្រពន្ធ័ស្រោចស្រពខ្នាតតូចការប្រើប្រាស់ទឹកងាយស្រួលពីព្រោះមានចំនួនកសិករតិចតួច គេអាចរៀបចំចាត់ចែងខ្លួនគេបាន។ ចំពោះប្រពន្ធ័ស្រោចស្រពមធ្យម និងធំ ការប្រើប្រាស់ទឹកមានការលំបាកច្រើន ដើម្បីរៀបចំ ពីព្រោះទឹកត្រូវហូរឆ្លងកាត់ប្រឡាយជាច្រើនខ្សែមុនពេលចូលទៅដល់ស្រែរបស់កសិករ ពេលខ្លះត្រូវរង់ចាំ ពីរ ឬ បីថ្ងៃ។

**អ្វីដែលហៅថាផែនការប្រើប្រាស់ទឹក?** គឺជាការរៀបចំផែនការស្រោចស្រព នៅពេលរៀបចំផែនការស្រោចស្រពត្រូវប្រជុំជាមួយកសិករជាមុនសិនដើម្បីជូនដំណឹងអំពីពេលវេលានិងបរិមាណទឹកសំរាប់ស្រោចស្រពឱ្យទៅគាត់បានច្បាស់លាស់។

- គណនាការផ្គត់ផ្គង់ទឹកសំរាប់ពេលអនាគត
- ការគណនាតំរូវការទឹកសំរាប់ដំណាំ
- ការផ្តល់ឱ្យស៊ីគ្នាជាមួយតំរូវការទឹកសំរាប់ប្រើប្រាស់

**សំនួរពិភាក្សា :** ហេតុអ្វីចាំបាច់ធ្វើផែនការ ក្នុងការប្រើប្រាស់ទឹកសំរាប់ប្រពន្ធ័ធារាសាស្ត្រ ?

## ២. និតិវិធីនៃការបែងចែកទឹក (ការអនុវត្ត)

វិធីសាស្ត្រ ក្នុងការបែងចែកទឹកមានលក្ខណៈខុសៗគ្នា ដែលកសិករធ្លាប់អនុវត្តនឹកន្លងមក :

- ➢ ការយកទឹកដោយសេរី ឬតាមសេក្តីត្រូវការស្រោចស្រពដែលកសិករអាចយកទឹកតាមតែចិត្តចង់បាន និងពេលណាដែលគេត្រូវការ។ តែជាសំណាងអាក្រក់ការបែងចែកទឹករបៀបនេះអាចដំណើរទៅបាននៅពេលណាមានទឹកច្រើន ហើយវាក៏ត្រូវការប្រឡាយធំដែរ។ ប៉ុន្តែជាញឹកញយនៅកណ្តាលរដូវតែងតែមានការខ្វះខាតទឹកនៅផ្នែកខាងចុងប្រឡាយព្រោះកសិករនៅដើមប្រឡាយបានប្រើប្រាស់ទឹកបានដោយសេរីតាមសេចក្តីត្រូវការ។
- ➢ ការបែងចែកតាមធារទឹក ឬសមាមាត្រទៅតាមការហូរក្នុងប្រពន្ធ័ធារាសាស្ត្រ ត្រូវបែងចែកតាមបរិមាណទឹកដែលត្រូវការជាក់ស្តែងរបស់ប្រពន្ធ័ស្រោចស្រពឬប្រឡាយទាំងមូលធ្វើរបៀបនេះកសិករទាំងអស់ទទួលបានបរិមាណទឹកស្មើគ្នាៗ ។
- ➢ ការបែងចែកតាមពេល ឬ ឆ្លាស់វេនគ្នាការបែងចែករបៀបនេះកសិករទាំងអស់ទទួលបានបរិមាណទឹកប្រើប្រាស់ពេញលេញ ប៉ុន្តែមិនស្ថិតក្នុងពេលតែមួយដូចគ្នាទេ ។

**សំនួរពិភាក្សា :**

- តើត្រូវជ្រើសការបែងចែកទឹក តាមវិធីណា បើប្រព្ន័ធស្រោចស្រព មួយមិនមានប្រឡាយគ្រប់គ្រាន់ ?
- តើត្រូវដោះស្រាយយ៉ាងណាខ្លះបើប្រពន្ធ័ស្រោចស្រពនោះមានការខ្វះទឹកជារៀងរាល់ឆ្នាំ ?

### ៣. គុណភាពទឹក

គុល្យភាពទឹកគឺជាធារទឹកផ្តល់សរុបសំរាប់ការដាំដុះ និងធារទឹកប្រើប្រាស់ជាក់ស្តែងក្នុងមួយរដូវ ។ តើកត្តាអ្វីខ្លះដែលធ្វើឱ្យបរិមាណទឹកមានការកើនឡើង ?

កត្តាដែលធ្វើឱ្យបរិមាណទឹកកើនឡើងមាន :

- បង្កើនសមត្ថភាពសំរាប់អាងស្តុកទឹកទុក ( ពង្រីកអាងឱ្យធំ )
- បង្កើនល្បឿនទឹកហូរពីទន្លេ ឬព្រែក ( ដោយសង់សំណង់បញ្ចូលទឹកឱ្យធំ រឺ ពង្រីកប្រឡាយឱ្យធំ )
- កត្តាភ្លៀងធ្លាក់

តើកត្តាអ្វីខ្លះដែលធ្វើឱ្យបាត់បង់ទឹក ?

- បាត់បង់ដោយការស្រូបយករបស់រុក្ខជាតិ
- បាត់បង់ដោយការជ្រាបចូលទៅក្នុងដីស្រែ ប្រឡាយ និងអាងទឹក ( ការជ្រាបចូលក្នុងដី )
- បាត់បង់ដោយរំហួត ពីក្នុងស្រែ ប្រឡាយ និងអាងទឹក ( ការហួតឡើងទៅលើអាកាស )
- ការខូចខាយ បាត់បង់តាមប្រឡាយ ឬ ស្រែ និងដោយខ្វះការគ្រប់គ្រង (គ្មានម្ចាស់ការ )

**៤. ការប្រើប្រាស់សំណង់ធារាសាស្ត្រ:** រាល់សំណង់ធារាសាស្ត្រមានមុខងារផ្សេងៗគ្នាដូចជាសំរាប់រក្សាទឹកទុកស្រោចស្រពនិងដោះទឹកនៅពេលមានជំនន់ខ្លាំងម្តងៗដើម្បីកុំឱ្យប្រព័ន្ធធារាសាស្ត្រខូចខាតធ្វើឱ្យវាមានដំណើរការ ។ បើផ្នែកណាមួយនៃសំណង់ត្រូវខូចខាតប្រើប្រាស់ពុំបានទេនោះវាអាចមានបញ្ហាដល់ការស្រោចស្រព ។ ដូច្នេះត្រូវមានផែនការដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រើប្រាស់នៅពេលណាត្រូវបិទ ហើយពេលណាត្រូវបើក ។

- **ក្នុងប្រពន្ធ័ធារាសាស្ត្ររួមមាន :** សំណង់នាំទឹក សំណង់ចែកចាយទឹក សំណង់ស្ទាក់ទឹក សំណង់បញ្ចេញទឹក សំណង់បំពង់បង្ហូរទឹកចូលស្រែ ប្រព័ន្ធប្រឡាយនាំទឹកស្រោចស្រព និងប្រព័ន្ធប្រឡាយដោះទឹក ។
- **ការប្រើប្រាស់អាងទឹកឬទំនប់:** មានន័យថារក្សាទឹកទុកមិនឱ្យលើសពីកំពស់សុវត្ថិភាព កាលណាបរិមាណទឹកលើសពីកំពស់សុវត្ថិភាពទឹកអាចហូរលើខ្នងទំនប់បណ្តាលឱ្យមានការហូរច្រោះបាក់ស្រុតសំណង់ ។
- **សំណង់ទ្វារទឹក-** កាលណាយើងបើកទ្វារចំហខ្លាំង ករណីខាងក្រោយសំណង់ប្រឡាយគ្មានទឹកធ្វើឱ្យមានការហូរ គួចនឹងអាចដាច់ភ្លឺប្រឡាយ ដូច្នេះយើងត្រូវបើកទ្វារទឹកសន្សឹមៗរហូតដល់ទឹកក្នុងប្រឡាយឡើងដល់កំរិតកំពស់មួយសមស្រប ។
- **ប្រឡាយនាំទឹក ឬ ប្រឡាយស្រោចស្រព :** ការប្រើប្រាស់ប្រឡាយមិនត្រូវឱ្យទឹកក្នុងប្រឡាយឡើងហួសពីកំពស់សុវត្ថិភាពទេ វាអាចបណ្តាលឱ្យទឹកហូរលើភ្លឺប្រឡាយ និងធ្វើឱ្យមានការហូរច្រោះភ្លឺប្រឡាយទៀតផង ។

### ៥. វិធីសាស្ត្រក្នុងការបើក រឺ បិទទ្វារទឹក

#### ៥,១- បើក រឺ បិទតាមតំរូវការ

- បើកទ្វារទឹកតាមតំរូវការស្រោចស្រព និងតាមកាលវិភាគបែងចែកទឹក

- បើកទ្វារទឹកតាមពេលវេលាដែលបានកំណត់តាមការគណនាខាងលើ
- បិទទ្វារទឹកនៅពេលទឹកគ្រប់គ្រាន់ដើម្បីរក្សាទឹកទុកពេលបន្ត

**៥,២-** បើក រឺ បិទសុវត្ថិភាព :

- បើកទ្វារទឹកមិនអោយលើសពីក្រិត្យដែលបានកំណត់
- បើកទ្វារទឹកទាំងអស់ក្នុងករណីតកំពស់អតិប្បរមានៅពេលទឹកជំនន់ រឺភ្លៀងខ្លាំង
- បើកទ្វារទឹកមិនអោយលើសពីកំពស់សុវត្ថិភាព
- ទំលាក់ទ្វាទឹកដោយសន្សឹមៗ ហើយគួររក្សាលំហូរក្នុងទ្វារទឹកណាមួយនៅក្នុងរដូវភ្លៀង អាស្រ័យទៅតាមការពិនិត្យកំពស់សុវត្ថិភាពរបស់អាង ។

# ផ្នែកទី ៥_ ការជួសជុល និង ថែទាំប្រព័ន្ធធារាសាស្ត្រ

## ១. សេចក្ដីផ្ដើម

ប្រព័ន្ធធារាសាស្ត្រមួយដែលគ្រោងប្លង់សាងសង់បានត្រឹមត្រូវ និងដំណើរការបានល្អដ៏រាបណាទទួលបាននូវការប្រើប្រាស់បានត្រឹមត្រូវ និងមានការថែទាំយ៉ាងយកចិត្តទុកដាក់បំផុត ។ មានន័យថាគ្មានការលេចធ្លាយ ច្រេះស៊ី ការហូរច្រោះ ឬការបាក់ដីក្នុងប្រឡាយ និងសំណង់សិល្បៈការផ្សេងៗនៅមានលក្ខណៈល្អស្អាត ឬមានផ្នែកនៃសំណង់សិល្បៈ ការត្រូវប្រេះស្រាំ ឬបែកបាក់ ។ ដើម្បីសំរេចបាននូវលទ្ធផលដូចខាងលើនេះ យើងត្រូវមាន ការថែទាំយ៉ាងទៀងទាត់ក៏ដូចជាការជួសជុលជាប្រចាំដែរ ។

## ២. ដំណើរការជួសជុល និងថែទាំអាងទឹក

ជាទូទៅអាងទឹកមានហេដ្ឋារចនាសម្ព័ន្ធរបស់វាដូចជា:

- ទំនប់ព័ទ្ធជុំវិញអាងទឹក
- ក្បាលហុងដោះទឹកដែលមានទ្វារទឹកសំរាប់បើក ឬ បិទទឹក
- លូ ឬ ទ្វារទឹកសំរាប់ជំនួយដល់ការដោះទឹកជំនន់ និងដោះកករបាតអាងដើម្បីបន្ថយការរាក់របស់អាង
- សំណង់បង្ហៀរសំរាប់ដោះទឹកជំនន់ចេញ និងដោះទឹកដែលលើសពីការកំណត់របស់អាងទឹក

### ២.១ ដំណើរការថែទាំទំនប់

**ការខូចខាត:**

- ជាទូទៅទំនប់គឺខូចខាតផ្នែកខ្នងលើ ដោយការធ្វើដំណើរ ការហូរច្រោះដាច់ដោយសារទឹកភ្លៀង
- ការសាងសង់មិនគ្រប់លក្ខណៈបច្ចេកទេស ( ជើងទេ ការបង្ហាប់មិនបានល្អ)
- ការខូចខាតជើងទេដោយការហូរបុកនៃចរន្តទឹកពីក្នុងអាង ឬរលក
- រួមផ្សំនៅពេលសាងសង់ការបង្ហាប់មិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ការយកដីមិនល្អធ្វើទំនប់ ។
- ការជ្រាបទឹកចេញពីក្នុងអាងតាមតួរទំនប់ និង ខ្វះបំពង់សំរាប់ដោះទឹកជ្រាបពីតួរទំនប់ ។



ជើងទំនប់ត្រូវបានច្រោះដាច់ដោយសារការហូរច្រោះ

**វិធានការ:**

- បញ្ចៀសអោយបាននូវការដឹកជញ្ជូនហួសកំណត់
- កសិករគួរប្រើប្រាស់រទេះកង់កៅស៊ូជំនួសកង់ដែក
- ការពារនូវការយកថ្មចេញពីជើងទេដោយសារការនេសាទត្រី និងសកម្មភាពផ្សេងៗ

- ចាក់បំពេញដីជាប្រចាំនៅកន្លែងដែលខូចខាតតិចតួច
- បញ្ចៀសការដឹកគោ ក្របីចុះឡើងលើជើងទេដែលគ្មានកាំជណ្ដើរឡើងចុះ

៣- <u>ការជួសជុល</u>

ក- ការជួសជុលជាប្រចាំ៖

- ចំពោះខ្នងទំនប់ ការជួសជុលតិចតួចជាប្រចាំដូចជាការចាក់គ្រួសក្រហមនៅកន្លែងមានប្រហោង ឬរន្ធជាដំបូង ត្រូវជីកបន្ថែមអោយបានជំរៅយ៉ាងតិច ២០ស.ម រួចបុកបង្ហាប់ និងស្រោចទឹកមួយស្រទាប់ម្ដងៗ ( មួយ ស្រទាប់ គឺ ១០ ស.ម)
- ចំពោះតួរទំនប់ នៅកន្លែងដែលមានរូងនាគ ត្រូវជីកក្រឡឹងជុំវិញ ហើយចាក់ដីគ្រួសក្រហមចូល
- ក្នុងករណីដែលបានពិនិត្យឃើញថាមានរូងនាគដែលបណ្ដាលមកពីការជ្រាបនៃចរន្តទឹកគឺត្រូវតែដាក់បំពង់ទុយោនៅកន្លែងដែលមានខ្សែទឹកហូរដោយចោះអោយមានប្រហោងតូចៗដើម្បីអោយទឹកជ្រាបចូលទៅក្នុងបំពង់ហើយហូរចុះទៅផ្នែកខាងក្រោមនៃតួរទំនប់
- ចំពោះរូងនាគច្រើនគួរធ្វើក្នុងទ្រង់ទ្រាយធំដោយអ្នកបច្ចេកទេសធារាសាស្ត្រ
- ចំណែកថវិការនឹងត្រូវចូលរួមដោយរដ្ឋាភិបាល និង ក.ក.ប.ទ/ស.ក.ប.ទ
- ក្នុងករណីដែល ក.ក.ប.ទ/ស.ក.ប.ទ ទើបតែចាប់ផ្ដើមហើយពុំទាន់មានលទ្ធភាពក្រសួងធនធានទឹក (រដ្ឋាភិបាល) និង ត្រូវពិចារណាលើបញ្ហានេះ
- ចំពោះជើងទេទំនប់ ជាពិសេសផ្នែកខាងមុខត្រូវពិនិត្យមើលដុំថ្ម (ករណីជើងទេរៀបថ្ម) ដែលធ្លាក់ ឬរសាត់ចេញពីជើងទេមកដាក់នៅកន្លែងដើមវិញ ហើយក្នុងករណីជើងទេដាំស្មៅ ត្រូវពិនិត្យមើលកន្លែងដែលចរន្តទឹក ឬរលកបុកដែលធ្វើអោយស្មៅដាច់ចេញពីជើងទេរ និងត្រូវដាំវិញជាបន្ទាន់ដោយការបោះបង្គោលស្នឹងពីលើ ដុំស្មៅ ដើម្បីចៀសវាងការរសាត់ដោយរលក ឬចរន្តទឹកបុក។

ខ- ការជួសជុលខួប

គួរធ្វើឡើងក្រោយពីការច្រូតកាត់នារដូវវស្សា ទៅលើការងារដូចខាងក្រោម

- ឈូសដីស្រទាប់លើចំកន្លែងដែលខូចខាតលើខ្នងទំនប់ ហើយចាក់ដីគ្រួសក្រហមរួមជាមួយការបង្ហាប់ និង ស្រោចទឹកជាស្រទាប់ៗផង
- តួរទំនប់ភាគច្រើនគឺបញ្ហារូងនាគដែលត្រូវជីកក្រឡឹងជុំវិញ មុននឹងបង្ហាប់ឡើងវិញ
- បើក្នុងករណីរូងនាគច្រើនជាប់ៗគ្នាគួរតែឈូសដីផ្នែកខាងលើចេញទាំងអស់ហើយចាក់ដីគ្រួសក្រហមចូលបំពេញវិញដោយបង្ហាប់ជាស្រទាប់ៗដូចដែលបានរៀបរាប់ខាងលើ

- ក្នុងករណីដែលបានពិនិត្យឃើញថាមានរូងនាគដែលបណ្តាលមកពីការជ្រាបនៃចរន្តទឹកគឺត្រូវតែដាក់បំពង់ទុយោនៅកន្លែងដែលមានខ្សែទឹកហូរដោយចោះអោយមានប្រហោងតូចៗដើម្បីអោយទឹកជ្រាបចូលទៅក្នុងបំពង់ហើយហូរចុះទៅផ្នែកខាងក្រោមនៃតួរទំនប់
- ជើងទេទំនប់ ការខូចខាតភាគច្រើននៅផ្នែកខាងមុខដោយការស៊ីដាច់ដោយរលក និងចរន្តទឹកបុក ជាទូទៅចរន្តទឹកនេះគឺបុកស៊ីដាច់នៅកន្លែងស្លាបស្ទើរគ្រប់សំណង់ទាំងអស់ ដូចនេះគួរតែចាក់ដីបំពេញនៅកន្លែងស៊ីដាច់ រៀបថ្មនៅលើជើងទេអោយបានវែង តភ្ជាប់ពីជញ្ជាំងស្លាបទៅដល់ផ្នែកខាងចុងនៃចរន្តទឹកបុក។ ដូចនេះការជួសជុលខួបគឺមានទ្រង់ទ្រាយធំ ដែលត្រូវការបច្ចេកទេស និងថវិកាច្រើនបន្តួរដែរ តែទោះជាយ៉ាងណាក៏ដោយការជួសជុលខួបគឺភាគច្រើនអាចធ្វើដោយ ក.ក.ប.ទ/ស.ក.ប.ទ ដោយមានការណែនាំពីមន្ត្រីបច្ចេកទេស។

ការជួសជុលខឿនប្រឡាយមេក្រោយពេលច្រូតកាត់



**គ- ការជួសជុលបន្ទាន់:**

ជាការថែទាំនៅពេលមានឧបទ្ទវហេតុកើតឡើង ដោយមិនបានគិតទុកមុនដោយកំលាំងអ្វីមួយជាទូទៅ គឺជាលទ្ធផលនៃការប្រើប្រាស់មិនសមរម្យ ភ្លៀងព្យុះខ្លាំង ដែលបង្កឡើងដោយធម្មជាតិ ។ល។ ហេតុការដែលកើតមានឡើងទាំងនោះ ត្រូវបានបញ្ឈប់កិច្ចដំណើរការរបស់ប្រព័ន្ធ ឬផ្នែកខ្លះនៃប្រព័ន្ធនោះ ត្រូវតែយកចិត្តទុកដាក់ដោយមិនមានការពន្យាពេលបានទេ។ ឧទាហរណ៏ដូចជាហេតុការដែលអាចកើតមានឡើង:

- ផ្នែកខាងលើភ្លឺប្រឡាយត្រូវបានទឹកជន់លិច
- ខូចខាតដែលកើតឡើងដោយចរន្តអគ្គីសនីនៅលើឧបករណ៏បញ្ជា
- ខូចខាតដោយរថយន្តធន់ធ្ងន់ទៅលើស្ពាន ឬ សំណង់
- ការធ្លុះធ្លាយដោយសារការរអិលធ្លាក់ផ្នែកខាងលើ និងខឿនប្រឡាយ
- ការរអិលធ្លាក់ចុះនូវសំណង់សំខាន់ៗ

ហេតុការណ៏ទាំងនោះមិនអាចទស្សន៏ទាយទុកមុនបានឡើយ ដូចនេះមូលនិធិបំរ៉ុងសំរាប់ថែទាំត្រូវយកមកបំពេញលើតម្លៃដែលត្រូវជួសជុល។

## ៤. ដំណើរការថែទាំក្បាលហុងទឹក

### ៤,១- ការខូចខាត

ជាទូទៅ ក្បាលហុងទឹកមិនមានការខូចខាតជាប្រចាំទេ តែអាចៈ

- របូត ឬ រលុងខ្ចៅទ្វារទឹក
- ស្ងួតប្រេងដែលធ្វើអោយគាំងពិញ៉ុង
- ស្ងួតកៅស៊ូរងដែលនៅសងខាងសំណង់
- ខូចពិញ៉ុងដោយមិនបានដាក់ខ្លាញ់គោជាប្រចាំ
- ខូចពិញ៉ុងដោយសារគាស់ទ្វារទឹកដោយប្រើដែក ឬកៅឡាក់ ។



ឧបករណ៍សំរាប់ដំណើរការទ្វារទឹកនៅដំណើរការល្អ



ឧបករណ៍សំរាប់ដំណើរការទ្វារទឹកត្រូវបានចោរលួច

### ៤.២- វិធានការ និង ការថែទាំ

- ក្បាលហុងទឹកដែលមានទ្វារដែក គួរតែពិនិត្យមើលពីការស្ងួតខ្លាញ់នៅគ្រប់ខ្ចៅ និងពិញ៉ុងទាំងអស់
- បញ្ចៀសអោយបាននូវការលួចគាស់ទ្វារទឹក
- ពិនិត្យមើលគ្រប់ខ្ចៅទាំងអស់ និងពិនិត្យវាអោយតឹងឡើងវិញ
- ពិនិត្យមើលដំណើរការរបស់វា លើការលើក និងទំលាក់ចុះ តើវាមានបញ្ហានៅកន្លែងណាដែរឬទេ?
- ក្បាលហុងទឹកដែលមានទ្វារឈើមានការខូចខាតច្រើនជាងទ្វារដែកដូចនេះការពិនិត្យមើលជាអចិន្ត្រៃត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើការរិតខ្ចៅជាប្រចាំ និងឃ្លាំមើលពីការលួចដោះពីជនខិលខូច ។

### ៤,៣- ការជួសជុលថែទាំ

- លាបថ្នាំច្រេះលើសន្ទះទ្វារទឹក
- ដាក់ខ្លាញ់លើដងវ៉ាន ពិញ៉ុង និងដែរវៃ
- ផ្លាស់ប្តូររ៉ងវ៉ាន់ និងកៅស៊ូទ្រនាប់ ឬ រ៉ងផ្សេងៗ

- ក្នុងករណីទ្វារទឹកឈើ គួរពិនិត្យ និងផ្លាស់ប្តូរអោយបានញឹកញាប់
- ពិនិត្យមើលបាតសំណង់ដើម្បីជួសជុលកំរាលមុខឈ្នាង
- ដុំថ្មពីមុខកំរាលត្រូវប្រមូលផ្តុំ និងបន្ថែមនៅកន្លែងដែលសង្កេតឃើញថាវាខ្វះ



ការជួសជុលដោយដាក់ខ្លាញ់ដងវ៉ាន និងពិញ៉ុង

## ៥. ដំណើរការថែទាំសំណង់បង្ហៀរ

### ៥.១ - ការខូចខាត

- ការហូរច្រោះដាច់នៅបាតសំណង់ដោយចរន្តទឹកនៅរដូវវស្សា
- ការខ្ទាតចេញនៃដុំថ្មដែលបណ្តាលពីចរន្តទឹកបុកខ្លាំងជាពិសេសគឺបណ្តាលពីការនេសាទដែលបានកាយដុំថ្មចេញដើម្បីចាប់ត្រី ។

### ៥.២- វិធានការ

- ហាមដាច់ខាតនូវការនេសាទប្រភេទណាមួយដែលកាយដុំថ្មចេញពីកន្លែងដើម
- ក្នុងករណីដែលកើតមានឡើងដោយចរន្តទឹកបុកត្រូវលើកវាមកដាក់នៅកន្លែងដើមវិញជាបន្ទាន់ដើម្បីជៀស វាងការស៊ីដាច់នូវផ្នែកខាងមុខ និងផ្នែកខាងក្រោយសំណង់ និងធ្វើអោយមានរូងនាគនៅបាតសំណង់

### ៥.៣- ការជួសជុល និងថែទាំ

- ជញ្ជូនថ្មដែលរសាត់ចេញមករៀបដាក់នៅកន្លែងដើមវិញជាបន្ទាន់ជាពិសេសនៅរដូវវស្សា
- ពិនិត្យមើលផ្នែកខាងមុខ និងបាតសំណង់ដើម្បីធ្វើការជួសជុលកំរាលមុខឈ្នាង ដុំថ្មពីមុខ និងក្រោយកំរាល ។

### ៦, ដំណើរការថែទាំប្រឡាយមេ និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រលាយមេ

ការថែទាំ និង ជួសជុលដោយមានផែនការច្បាស់លាស់ធ្វើឱ្យការប្រើប្រាស់ប្រឡាយមាននិរន្តរភាព។ ពេលវេលាជួសជុល ប្រឡាយល្អបំផុត គឺនៅរដូវប្រាំងទោះបីប្រឡាយកំពង់ប្រើប្រាស់ក៏ដោយក៏ចរន្តទឹកនៅរដូវប្រាំង មានកំរិតតិចជាង ២០ ភាគរយនៃធារទឹកអតិបរិមាដែលមិនអាចប៉ះពាល់ខ្លាំងដល់ការងារជួសជុលឡើយ។




សកម្មភាពជួសជុល និងថែទាំប្រឡាយដោយសមាជិក ក.ក.ប.ទ នៅតំបន់គំរូ កណ្តាលស្ទឹង ខេត្តកណ្តាល




សកម្មភាពជួសជុល និងថែទាំប្រឡាយដោយសមាជិក ក.ក.ប.ទ តាមប្លុក




សកម្មភាពជួសជុល និងថែទាំប្រឡាយដោយសមាជិក ក.ក.ប.ទ ក្នុងអំឡុងពេល និងក្រោយពេលដាំដុះ





សកម្មភាពជួសជុល និង ដាក់បំពង់ជ័របង្ហូរទឹកចូលស្រែដើម្បីងាយស្រួលគ្រប់គ្រងទឹក
និងថែរក្សាស្ថានភាពដើមរបស់ប្រឡាយ

**៦,១- បញ្ហាទូទៅរបស់ប្រឡាយតែងតែរងនូវការខូចខាតដូចខាងក្រោមនេះ**

- មិនខុសពីខ្នងទំនប់ប៉ុន្មានទេ ខ្នងប្រឡាយមេតែងតែរងនូវការខូចខាតដោយការដឹកជញ្ជូនលើសទំងន់ និងការប្រើប្រាស់រទេះគោរបស់កសិករមានកង់ដែកធ្វើអោយស៊ីដាច់ដីលើខ្នងប្រឡាយ
- ជើងទេប្រឡាយមានការស៊ីដាច់ខ្លាំងនៅពីខាងមុខ និងក្រោយសំណង់សិល្បៈការនានា
- ជើងទេប្រឡាយផ្នែកខាងក្នុងត្រូវបានស៊ីដាច់ដោយចរន្តទឹកហូរ និងដឹកគោក្របីចុះឡើងតាមជើងទេ
- តួរប្រឡាយភាគច្រើនគឺខូចខាតធំៗនៅត្រង់ចំណុចសំណង់សិល្បៈការដោយសារជញ្ជាំងស្លាបមិនធានាដល់ការបុកដោយចរន្តទឹក
- ការបើកទឹកហួសពីកំរិតសុវត្ថិភាពដែលធ្វើអោយស៊ីដាច់ផ្នែកជញ្ជើមខាងលើនៃជើងទេប្រឡាយ

**៦,២- វិធានការសំរាប់ការពារកុំអោយខូចខាតប្រឡាយ**

- ហាមរថយន្តធំៗ និងរថយន្តផ្ទុកហួសទំងន់
- ហាមឃាត់ការនេសាទត្រីនៅពីខាងមុខ ឬ ពីក្រោយសំណង់ខុសច្បាប់ដែលកកាយយកដុំថ្មចេញពីជើងទេ ប្រឡាយ
- បើកទឹកមិនអោយលើសពីល្បឿនអតិបរិមា
- នៅពេលបើកទឹកត្រូវអង្កេតមើលកំពស់ទឹកសុវត្ថិភាពក្នុងប្រឡាយ
- ត្រូវតែមានកាំជណ្តើរសំរាប់ដឹកគោក្របីឡើងចុះលើប្រឡាយ
- ត្រូវដឹកគោក្របីឆ្លងកាត់ប្រឡាយតាមសំណង់ស្ពាន
- ត្រូវអោយកសិករយល់ដឹងជាទូទៅពីរបៀបការពារប្រឡាយ

### ៦,៣- ការជួសជុលកន្លែងខូចខាតនៃប្រឡាយ

- កាយដីជុំវិញកន្លែងស៊ីដាច់ដែលដីមិនមានភាពស្អិតជាប់គ្នា និងពិនិត្យមើលទំហំដែលងាយស្រួលក្នុងការបង្ហាប់
- ក្រាលកំរាលថង់ប្លាស្ទិចនៅពីលើកន្លែងច្រោះដាច់
- ចាក់ដីស្អិតចូលរួចបង្ហាប់ដូចដែលបានណែនាំ
- ប្រសិនបើ គ្មានថង់ប្លាស្ទិចគួរតែយកដីគ្រួសក្រហមដែលស្អិត
- ពង្រីកមុខទឹក និងមុខឈ្នាងព្រមទាំងជញ្ជាំងស្លាបអោយបានធំ និងវែងបន្ថែមទៀត
- រៀបថ្មនៅពីមុខកំរាលអោយបានវែង ទាំងខាងមុខសំណង់ និងក្រោយសំណង់
- ប្រសិនបើជើងទេខូចទ្រង់ទ្រាយគួរតែចាក់ដីបំពេញរួចបង្ហាប់ ហើយដាំស្មៅឡើងវិញ




ជួសជុលកន្លែងធ្លុះធ្លាយដោយសមាជិក ក.ក.ប.ទ

## ៧- សំណង់សិល្បៈការក្នុងប្រឡាយ

### ៧,១- សំណង់សិល្បៈការតែងតែរងនូវការខូចខាតដូចខាងក្រោម៖

- ការស៊ីដាច់នៅពីមុខសំណង់ដោយចរន្តទឹកបុក ដោយការដឹកហួសទំងន់ឆ្លងកាត់លើសំណង់សិល្បៈការ
- ការសាងសង់ខុសលក្ខណៈបច្ចេកទេស
- រលុង និងខូចខ្ទៅ
- ការលួចគាស់ទ្វារទឹកដោយប្រើដែកគាស់
- ការខូចខាតពិញ្ចុំងដោយមិនដាក់ខ្នាញ់
- ដងរ៉ានរៀចដោយរវៃហួសកំរិត
- ចោរលួចផ្នែកនៃគ្រឿងបង្គុំនៃទ្វារទឹក



ជញ្ជាំងស្លាបត្រូវបានច្រោះដាច់ដោយសាចរន្តទឹក

**៧,២- វិធានការដើម្បីការពារការខូចខាតនៃសំណង់សិល្បៈការ**

- ហាមរថយន្តធំៗ និងរថយន្តផ្ទុកទំងន់ហួសទំងន់
- ហាមខាត់ការនេសាទត្រីនៅពីខាងមុខ ឬ ពីក្រោយសំណង់ខុសច្បាប់ដែលកកាយយកដុំថ្មចេញពីជើងទេ ប្រឡាយ
- បើកទឹកមិនអោយលើសពីល្បឿនអតិបរិមា
- នៅពេលបើកទឹកត្រូវអង្កេតមើលកំពស់ទឹកសុវត្ថិភាពក្នុងប្រឡាយ
- ត្រូវដឹកគោក្របីឆ្លងកាត់ប្រឡាយតាមសំណង់ស្ពាន
- ត្រូវអោយកសិករយល់ដឹងជាទូទៅពីរបៀបការពារប្រឡាយ

**៧,៣- ការត្រួតពិនិត្យថែទាំ និង ជួសជុលសំណង់សិល្បៈការ**

សំណង់សិល្បៈការជាផ្នែកមួយនៃប្រពន្ធ័ធារាសាស្ត្រ ដែលធ្វើឡើងដោយបេតុងអាមេរ៍ ការថែទាំសំណង់សិល្បៈការមានដូចខាងក្រោម :

- **ប្រចាំថ្ងៃ** - ពិនិត្យដំណើរការសំណង់ ពិនិត្យវ៉ានរវៃ ខ្មៅ ស៊ី ខ្លាញ់ និងពិនិត្យបន្ទះទ្វារ លាបថ្នាំ កៅស៊ូវ៉ង
- **ប្រចាំសប្តាហ៍:**
  - វិតឡើងវិញផ្នែកទ្វារទឹកនូវប៊ូឡុង និងខ្មៅទាំងឡាយដោយប្រើសោរវិត សំអាតរួចដាក់ខ្លាញ់ នៅផ្នែកដែលកក ។
  - ធ្វើកំណត់ហេតុពីការត្រួតពិនិត្យ ប្រចាំសប្តាហ៏កន្លងមក
  - ធ្វើកំណត់ហេតុ ពីយោបល់ទូទៅរបស់អ្នកប្រើប្រាស់ អំពីការបើកបិទទ្វារទឹក និង បញ្ហាផ្សេងៗ ។

- **ប្រចាំខែ**

 - ពិនិត្យកិរិតសមត្ថភាពសំណង់ ការហូរច្រោះ ការស្រុត ការរអិល ការបិទបើកទ្វារទឹកបានល្អ រឺពុំបានល្អ ។

 - ពិនិត្យសមត្ថភាពកន្លែងបន្ថយចរន្តទឹក (Stilling Basin) ជួសជុលក្នុងករណីបាក់ស្រុត ។

- **ប្រចាំឆ្នាំ**

 - រើដោះចេញសំណុំទ្វារទឹកទាំងមូល វ៉ាន ធ្មេញស្ពី បន្ទះទ្វារ កៅស៊ូ

 - សំអាត និង ពិនិត្យគ្រឿងបង្គំទាំងអស់

 - ធ្វើកំណត់ហេតុពីលក្ខណះរបស់គ្រឿងបង្គំទាំងនោះ

 - ប្តូរខ្មៅ និងប៊ូឡុងដែលមានច្រេះស៊ី

 - ប្តូរគ្រឿងដែក បេតុង ដែលសឹកដាច់

 - ដាក់ខ្លាញ់អោយបានស្អាតនៅពេលដែលគ្រឿងបង្គំត្រូវបានរៀបចំឡើងវិញ

 - ពិនិត្យពីដំណើរការរបស់សំណង់ឡើងវិញដោយការបើក បិទទ្វារទឹកសាកល្បង

 - រៀបចំថ្មដែលបានដាក់នៅជុំសំណង់ឡើងវិញ

 - សំអាតព្រៃដែលដុះ នៅជុំសំណង់អោយបានស្អាត ។

 - ស្តារភក់ រឺ ដីល្បាប់ចេញពីកន្លែងពិនិត្យចរន្តទឹក ( Stilling Basin) អោយបានស្អាត ។

 - រៀបចំផ្លាកសញ្ញា ហាមឃាត់ រឺ បំរាមផ្សេងៗដែលចាំបាច់ដាក់នៅទីនោះ

ប្រសិនបើមានស្នាមប្រេះលេចឡើងនៅលើជញ្ជាំង ( Wall) រឺកន្លែងបន្ថយចរន្តទឹក ( Stilling-Basin) និងផ្នែកផ្សេងៗទៀតនៃសំណង់យើងត្រូវៈ

 - ផ្សើមទឹកបន្តិចទៅក្នុងស្នាមប្រេះនោះ ហើយកេះវាអោយស្អាត

 - រោយស៊ីម៉ង់សុទ្ធចូលទៅក្នុងស្នាមប្រេះនោះដើម្បីអោយវាចាប់គ្នា

 - រួចលាយបាយអរ ( ស៊ីម៉ង់ ១ ខ្សាច់ ៤) យកទៅបញ្ចូលកន្លែងដែលប្រេះនោះអោយបានណែនល្អ ហើយយកក្តារវីអោយបានស្អាតជាការស្រេច ។

➢ ប្រសិនបើប៊ូឡុង ខ្មៅ ជើងវ៉ានណាមួយរបូត រឺ ដាច់ជាប់នៅក្នុងបេតុង

 - ដកវ៉ាន រឺ ទ្វារទឹកឡើងលើហើយដកបូឡុង រឺខ្មៅនោះចេញ

 - សំអាតកន្លែងបេតុងដែលបែក

 - ញាត់ស៊ីម៉ង់ស្ងួត ចូលក្នុងរន្ធនោះទុកអោយរឹង

 - យកបូឡុងថ្មីមកវិតបញ្ចូលកន្លែងរន្ធនោះវិញដោយប្រុងប្រយត្ន័

➢ ប្រសិនជាដុំថ្មណាមួយរបូត រឺ ខ្ទាតចេញឆ្ងាយពីសំណង់បេតុងដោយចរន្តទឹករុញ

 - រើសដុំថ្មនោះមកដាក់កន្លែងដើមវាវិញ

- ដាក់ថ្មបន្ថែម នៅកន្លែងដែលមានសភាពស្រុត

**ប្រការខ្លះៗដែលអ្នកប្រើប្រាស់ប្រពន្ធ័អាចដោះស្រាយដោយខ្លួនឯង**

| ហេតុការណ៍ | មូលហេតុ | ដំណោះស្រាយ |
|---|---|---|
| ទឹកហូរពុំបានស្រួល | - មែកឈើ រឹកំទិចកំទីរុក្ខជាតិអណ្តែត មកកកស្ទះខាងមុខសំណង់ | - យកឈើវែងដែលមានទំពក់ខាងចុងមកខ្វារ |
| មានការហូរច្រោះខាងក្រោយសំណង់ | - បើកទឹកច្រើនពេកហួសតំរូវការ | - មុនបើកទ្វារទឹកត្រូវពិនិត្យតារាងកម្មវិធីនៃការប្រើប្រាស់ទឹក |
| ទ្វារទឹកពិបាកបិទបើក និងមានទឹកលិចជាអចិន្ត្រៃយ៍ | - កៅស៊ូទ្រនាប់ទ្វារងាប់<br>- ស្ងួតខ្លាញ់ រឺ ប្រេង<br>- រវៃញាប់ពេក | -ផ្លាស់កៅស៊ូថ្មី<br>-ដាក់ខ្លាញ់ រឺ ប្រេងឡើងវិញ<br>-រវៃតាមធម្មតា |

**៧,៣-ការថែទាំទ្វារទឹករួមមាន:**

ដាក់ខ្លាញ់គោកន្លែងកកិតនៃទ្វារទឹក លាបថ្នាំបង្កាន់ដៃទ្វារទឹក និង លាបថ្នាំបន្ទះទ្វារទឹក

**៧,៤- ការថែទាំលូឆ្លងកាត់ផ្លូវ**

សំណង់លូឆ្លងកាត់ផ្លូវតែងតែរងនូវការខូចខាតដូចខាងក្រោម:

- ដឹកសំភារ:លើសទំងន់ឆ្លងកាត់លើលូ
- ដាក់លូមិនត្រឹមត្រូវតាមលក្ខណ:បច្ចេកទេស
- ហូរច្រោះបាតលូដោយមិនបានដាក់ថ្មតំរៀបពីខាងមុខ
- មិនដាក់ថ្មនៅពីក្រោយ និងខាងមុខលូ
- ការនេសាទខុសច្បាប់ដែលបានកាយថ្មចេញពីមុខ និងក្រោយលូដែលបណ្តាលអោយទឹកហូរស៊ីរូងបាតក្រោមលូ





ការជួសជុល និងសាងសង់សំណង់លូដោយសមាជិក ក.ក.ប.ទ

## ៨- ការងារធ្វើរបាយការណ៍

វាគឺសំខាន់ណាស់ដែលមានកំណត់ហេតុពីការងារទាំងអស់ដែលត្រូវបានអនុវត្តកន្លងមក ។ របាយការណ៍នេះភ្ជាប់ ជាមួយនូវឯកសារបញ្ជាក់ពីការងារថែទាំដែលត្រូវបានអនុវត្តដោយយោងទៅតាមនិតិវិធីថែទាំគំរូ ។ ទំរង់នេះត្រូវបានបំពេញសំរាប់កិច្ចសន្យានិមួយៗហើយជាឯកសារយោងក្នុងការចុះបញ្ជីថែទាំ ។ លិខិតគួរតែកែតម្រូវនៅពេលការងារបានបញ្ចប់ ។

## ៩- ការរៀបចំផែនការជួសជុល និងថែទាំ

<u>របៀបគំរូសំរាប់រៀបចំផែនការថែទាំជាក់ស្តែង</u>

ការថែទាំ និងជួសជុលជាក់ស្តែងនិងត្រូវបានអនុវត្តដោយផ្អែកលើឯកសារដែលបង្កើតពតិមានបន្តបន្ទាប់ដូចខាងក្រោម

### ៩.១. ស្ថានភាពបច្ចុប្បន្ននៃការថែទាំ

- ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធ
- សរុបពីការងារថែទាំនៅកំឡុងពេលបច្ចុប្បន្ន រួមបញ្ចូលជាមួយនឹងបញ្ជីឈ្មោះសមាសភាព ។ ការពង្រីក និង ការប៉ាន់ប្រមាណនៃលទ្ធផលត្រូវបានបង្កើតឡើង ។
- ការងារពន្យាពេល

### ៩.២ រៀបចំកម្មវិធីថែទាំ

- កំណត់ពេលវេលាលើការងារថែទាំ
- មូលនិធិអាចដំណើរការសំរាប់ការងារថែទាំ
- យុទ្ធសាស្ត្រក្នុងការថែទាំ
- ដាក់ការងារជាអាទិភាព
- រៀបចំកម្មវិធីលើការងារថែទាំ បញ្ជីឈ្មោះសមាសភាព និងនិតិវិធីថែទាំគឺត្រូវបានប្រតិបត្តិ និងការប៉ាន់ស្មានតម្លៃ ។
- ត្រៀមសំភារៈបំរុងសំរាប់ថែទាំបន្ទាន់
- ប្រតិទិនសំរាប់ការងារថែទាំ
- ការងារដែលត្រូវពន្យាពេល

### ៩. ៣- បែបបទគំរូសំរាប់ការរៀបចំផែនការថែទាំជាក់ស្តែង

បែបបទត្រូវបានស្នើឡើងសំរាប់ការរៀបចំផែនការថែទាំប្រចាំឆ្នាំគឺជាវិធីដដែលៗដូចដែលបានពិពណ៌នាសង្ខេបខាងក្រោមនេះ

<u>ជំហាននៅក្នុងកិច្ចដំណើរការរៀបចំផែនការនៅឆ្នាំដំបូងនៃកិច្ចដំណើរការគឺដូចខាងក្រោម:</u>

១) - ការត្រួតពិនិត្យសមាសភាពនៃប្រព័ន្ធ។ ត្រួតពិនិត្យលក្ខខ័ណក៏រិតអនុញ្ញាតពីសមាសភាពនៃប្រព័ន្ធ ធារាសាស្រ្ត។

២) - សមាសភាពសំរាប់ថែទាំនិមួយៗជាតម្រូវការត្រូវបានជ្រើសរើសឡើង។

៣) - ទំហំនៃការងារថែទាំត្រូវប៉ាន់ស្មានឡើងដោយការអនុវត្តតាមតម្រូវការជាក់ស្តែង (ជាម៉ែត្រ ឬនិតិវិធីជាក់ស្តែង ទៅលើសមាសភាពដែលបានជ្រើសរើសឡើង)។

៤) - តម្លៃថែទាំត្រូវបានកំណត់ដោយយកទំហំការងារគុណជាមួយតម្លៃរាយ

៥) - នេះគឺធ្វើសំរាប់សមាសភាពប្រព័ន្ធធារាសាស្រ្តទាំងអស់ ហើយតម្លៃប៉ាន់ប្រមាណសរុបនៃតម្រូវការថែទាំគឺត្រូវ បានគណនាឡើង។

៦) - ប្រសិនបើមូលនិធិអាចប្រើប្រាស់សំរាប់តម្រូវការថែទាំត្រូវបានលើសពីតម្រូវការសរុបនេះបន្ទាប់មកការងារថែ ទាំអាចអនុវត្តបានទាំងអស់ ហើយផែនការថែទាំគឺរៀបចំដើម្បីបញ្ជូនអោយធ្វើការយល់ព្រម។

៧) - ម្យ៉ាងទៀតប្រសិនបើមូលនិធិសំរាប់ថែទាំគឺតិចជាងតម្លៃប៉ាន់ប្រមាណសរុប បន្ទាប់មកការជ្រើសរើសត្រូវតែធ្វើ ក្នុងចំណោមដែលបានជ្រើសរើសដើម្បីកាត់បន្ថយតម្លៃថែទាំសរុប។

វិធីនេះគឺត្រូវបានបន្តរហូតដល់ការប៉ាន់ប្រមាណ តម្លៃអោយត្រូវនឹងមូលនិធិអាចប្រើប្រាស់បាន។ ការជ្រើស រើសត្រូវបានកើតឡើងដោយផ្តល់អាទិភាពដំបូង។

៨) - មានម្តងម្កាលតុល្យភាពរវាងតម្លៃ និងមូលនិធិអាចប្រើប្រាស់បាន ហើយផែនការថែទាំប្រចាំឆ្នាំគឺត្រូវបានពួន អោយធ្វើការយល់ព្រម ក្រោយពីយល់ព្រមផែនការត្រូវបានអនុវត្ត។

ការត្រួតពិនិត្យអាចត្រូវបានអនុវត្តដោយផ្អែកទៅលើការវិនិច្ឆ័យដំដែលៗនៅក្នុងឆ្នាំបន្ទាប់ រឺក៏មន្ទីរធនធាន ទឹក និង ឧតុនិយម រឺ ស.ក.ប.ទ អាចផ្តល់ការណែនាំទៅលើការថែទាំជាអាទិភាពឬចំនុចដែលត្រូវយកចិត្តទុក ដាក់។

# ផ្នែកទី ៦. ការរៀបចំថវិកា សម្រាប់ថែទាំ

## ១. ការទទួលខុសត្រូវនៃការរៀបចំផែនការថែទាំ

ថវិការសំរាប់ថែទាំ គឺត្រូវបានរួមបញ្ចូលក្នុងផែនការការងារប្រចាំឆ្នាំដែលត្រូវបានព្រមព្រៀងជាមួយគ្នា ដោយគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ។ ការទទួលខុសត្រូវលើការរៀបចំថវិការសំរាប់ថែទាំរបស់ ក.ក.ប.ទ/ស.ក.ប.ទ ដែលបានគ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធធ្វើការសំរេចជាមួយគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ដោយយោងទៅលើស្ថានភាព ក.ក.ប.ទ/ស.ក.ប.ទ។ គាត់គួរតែដឹកនាំផ្តួចផ្តើមគំនិត និងចាត់ចែងការរៀបចំថវិការថែទាំហើយនឹងរាយការណ៍ទៅប្រធានគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ។ គាត់គឺត្រូវបានជួយដោយសមាជិកអនុក្រុមកសិករប្រើប្រាស់ទឹក (អ.ក,ក.ប.ទ) សមាជិក ផ្សេង១ទៀតនៃគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ប្រធាន ក.ក.ប.ទ/ស.ក.ប.ទ ក្នុងការចាត់ចែងការងារនេះ។ ក្រោយមក គឺជាការទទួលខុសត្រូវសំរាប់ការរៀបរាប់លំអិតពីបច្ចេកទេស។ មន្ទីរធនធានទឹកពិនិត្យពិច្ច័យលើការរៀបចំថវិកា ថែទាំ សំរាប់ហេដ្ឋារចនាសម្ព័ន្ធមេ។ តារាងនេះត្រូវបានអនុវត្តដោយអ្នកបច្ចេកទេសគំរោង និងជំនួយការរបស់គាត់ នៅក្រោមការចាត់ចែងពីវិស្វករធារាសាស្ត្រខេត្ត។

<u>ប្រតិទិនសំរាប់ការរៀបចំផែនការថែទាំ</u>

ប្រតិទិនសំរាប់ការរៀបចំថវិការថែទាំសំរាប់ហេត្ថារចនាសម្ព័ន្ធមេ ប្រឡាយរង ប្រឡាយដោះទឹក និង ផ្លូវ មានបង្ហាញក្នុងតារាងខាងក្រោម:

- ការរាយឈ្មោះដំបូងគឺប៉ាន់ស្មានសំរាប់ឆ្នាំបន្ទាប់នៅពេលអ្នកបច្ចេកទេសគំរោងបញ្ជូនការប៉ាន់ប្រមាណនេះទៅវិស្វករធារាសាស្ត្រខេត្តមិនអោយហួសពី ថ្ងៃទី១ ខែ តុលា ដោយឆ្លងតាមប្រធានការិយាល័យធនធានទឹកស្រុក។
- ការចាត់ចែងថវិកាសំរាប់ការងារថែទាំទៅលើហេដ្ឋារចនាសម្ព័ន្ធមេ ដែលទាក់ទងទៅនឹងថវិការប្រចាំឆ្នាំដែលផ្តល់ដោយនាយកដ្ឋាន ហិរញ្ញវត្ថុទៅមន្ទីរធនធានទឹក និង ឧតុនិយមខេត្ត អោយបានឆាប់ក្រោយពីបិទថវិកាប្រចាំឆ្នាំនៅថ្ងៃទី ៣១ ខែ ១២។ បន្ទាប់មកអ្នកបច្ចេកទេសគំរោង នឹងអនុវត្តការសិក្សាអង្កេត និងត្រួតពិនិត្យបញ្ចប់ដើម្បីប្រមូលទិន្នន័យសំរាប់រៀបចំពីការប៉ាន់ប្រមាណលំអិតនៃការងារថែទាំ។ ការប៉ាន់ប្រមាណនេះគឺត្រូវបានស្នើទៅវិស្វករខេត្ត និង ត្រូវបានផ្តល់ជាអាទិភាព ហើយត្រូវបានអនុម័តដោយ យោងទៅលើសិទ្ធអំណាចនៃរដ្ឋបាលហិរញ្ញវត្ថុ។ ដំណើរការនេះគឺត្រូវបានគ្រប់គ្រងបន្តបន្ទាប់ដូចជាការចំណាយទាំងអស់ គឺលើរដ្ឋាភិបាល និង ថវិការខេត្ត។

ប្រតិទិនសំរាប់រៀបចំថវិការថែទាំហេដ្ឋារចនាសម្ព័ន្ធមេ ប្រឡាយរង ប្រឡាយដោះទឹករង និងផ្លូវថ្នល់

| ស្នើសុំថវិការ | អ្នកបច្ចេកទេសគំរោង | វិស្វករធារាសាស្ត្រខេត្ត | ប្រធានមន្ទីរធនធានទឹក |
|---|---|---|---|
| ថ្ងៃ-ខែ ស្នើសុំ | ១/១០ | ៣១/១០ | ១៥/១១ |

- ប្រតិទិនសំរាប់ការរៀបចំថវិការថែទាំសំរាប់ប្រឡាយរងទី១ និងហេដ្ឋារចនាសម្ព័ន្ធប្លុកប្រឡាយរងទី២:

ហេដ្ឋារចនាសម្ព័ន្ធប្លុកប្រឡាយរងទី២ត្រូវថែទាំដោយក.ក.ប.ទ/ស.ក.ប.ទ ការចាត់ចែងរៀបចំថវិការយោងទៅលើការណែនាំពីគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ។ គាត់បញ្ជូនការប៉ាន់ស្មានរបស់គាត់ទៅប្រធាន ក.ក.ប.ទ/ស.ក.ប.ទ មិនអោយលើសថ្ងៃទី ១ ខែ តុលា។ គាត់បញ្ជូនលិខិតស្នើសុំទៅវិស្វករធារាសាស្ត្រខេត្ត នៅថ្ងៃទី ៧ ខែ តុលា ថវិកាត្រូវបានយល់ព្រមតាមលក្ខណៈបច្ចេកទេសសំរាប់ថែទាំគឺត្រូវបញ្ជូនទៅហិរញ្ញិកនៃ ក.ក.ប.ទ/ស.ក.ប.ទ ដែលរួមបញ្ចូលជាមួយកម្មវិធីប្រចាំឆ្នាំ។ ការប៉ាន់ស្មាននេះគឺត្រូវបានបង្ហាញទៅគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ដើម្បីយល់ព្រម។

ឧទាហរណ៏: ប្រតិទិនរៀបចំផែនការថែទាំប្រឡាយរងទី១ និងហេដ្ឋារចនាសម្ព័ន្ធប្លុកប្រឡាយរងទី២

| ស្នើសុំថវិកា | អ្នកចាត់ចែង | ប្រធាន ក.ក.ប.ទ/ ស.ក.ប.ទ | វិស្វករធារាសាស្ត្រឱ្យការណែនាំ | គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ |
|---|---|---|---|---|
| ស្នើសុំថវិកា | ១/១០ | ១៥/១០ | ២១/១០ | ២១/១១ |

## ២_ការគ្រប់គ្រងហិរញ្ញវត្ថុ

ផ្នែកខ្លះនៃប្រព័ន្ធភាគច្រើនត្រូវបានខូចខាតនិងទ្រុឌទ្រោមយ៉ាងឆាប់រហ័សដោយសារការចូលរួមរបស់កសិករនៅមានកំរិត ម្យ៉ាងទៀតជារឿយៗពលកម្មរបស់កសិករបានចំណាយដោយមានការស័គ្រចិត្ត។ ក្រោមលក្ខខ័ណ្ឌនេះ គឺត្រូវការធនធានជាចាំបាច់សំរាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដែលមានតែពលកម្ម សំភារៈ មូលដ្ឋាន និងការចូលរួមផលិតផលស្រូវ។

### ២.១. ការប៉ាន់ប្រមាណធនធានដែលត្រូវការ

ជំហានទីមួយក្នុងការរៀបចំការប៉ាន់ប្រមាណធនធានដែលត្រូវការគឺត្រូវរៀបចំពង្រាងផែនការសេវាកម្មស្រោចស្រពមួយ។ នៅពេលរៀបចំរួចហើយគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវវាយតម្លៃពីធនធាន

ដែលត្រូវការដើម្បីអនុវត្ត។ គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវសំរេចលើការផ្តល់ទឹកថាតើខ្លួនត្រូវប្រើបុគ្គលិកពិសេសដើម្បីចែកចាយទឹកពីប្រព័ន្ធទៅស្រែ ឬត្រូវឱ្យកសិកររៀបចំការចែកចាយទឹក ដោយខ្លួនឯងតាមការស្ម័គ្រចិត្ត ដោយមិនមានការទទួលប្រាក់កំរៃ។ ប្រសិនបើត្រូវការបុគ្គលិកពិសេស គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវសំរេចលើកំរៃលើបុគ្គលិកទាំងនោះជាប្រាក់ ជាផលិតផល ឬធនធានឯទៀត នៅក្នុងឃុំ។ល។ ប្រសិនបើការចែកចាយ ទឹកត្រូវធ្វើដោយកសិករខ្លួនឯងត្រូវធ្វើបទបញ្ញត្តិដែលងាយយល់ និងច្បាស់លាស់ដល់ពួកគេទាំងអស់។ គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវសំរេចអំពីសកម្មភាពណាដែលត្រូវធ្វើជាពលកម្មដោយមិនយកកំរៃ យកកំរៃតែពលកម្មពិសេស និងគ្រឿងចក្រ។ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវសំរេចពីពលកម្មពិសេសណាមួយដែលត្រូវបង់ចំណាយ ជាប្រាក់ជាការស្ម័ក្រចិត្ត (ដូចជាវិភាគទាន ផលិតផល) ឬដោយមធ្យោបាយដ៏ទៃទៀត។ បន្ទាប់មក ក.ក.ប.ទ/ស.ក.ប.ទ ធ្វើបញ្ជីរួមអំពីតម្រូវការធនធានសំរាប់សកម្មភាពទាំងអស់ដោយបង្ហាញ ពីចំនួនប្រាក់ពលកម្មសំភារៈដែលត្រូវចំណាយ ឬទំរង់បែបបទផ្សេងទៀតនៃការចេញថ្លៃដែលត្រូវផ្តល់។ ក.ក.ប.ទ/ស.ក.ប.ទ គួរបង្ហាញដល់សមាជិក ដើម្បីសំរេចឬកែតម្រូវ។

**២.២. ការប្រមូល និងបែងចែកធនធាន**

ក.ក.ប.ទ/ស.ក.ប.ទ គួររៀបចំការប្រមូលធនធានសំខាន់ៗទាំងអស់(ជាប្រាក់ពលកម្ម ឬអ្វីផ្សេងទៀត) តាមកម្មវិធីដែលនឹងឱ្យអនុវត្តសេវាកម្មផ្តល់ទឹកបង្ហូរ និងថែទាំបានទាន់ពេលវេលាប្រសិនបើ ក.ក.ប.ទ/ស.ក.ប.ទ សំរេចថាប្រមូលជាប្រាក់ ឬការបង់ចំណាយតាមការស្ម័គ្រចិត្ត (ដូចជាបរិមាណស្រូវ/ហត)ពីសមាជិករបស់ខ្លួន បន្ទាប់មក ក.ក.ប.ទ/ស.ក.ប.ទ ត្រូវសំរេចលើចំនួនប្រមូលពីសមាជិកម្នាក់ៗ ហើយត្រូវប្រមូលរបៀបណា។ ចំនួនដែលត្រូវប្រមូលគួរគ្រប់គ្រាន់សំរាប់បង់តម្លៃដែលបានគិតទុក។ នៅពេលអនាគត ជាពិសេសនៅពេលផលិតភាពសេដ្ឋកិច្ចនៃធារាសាស្ត្រកសិកម្មបានកែលំអរហើយកសិករអាចមានធនាគារប្រើប្រាស់ ក.ក.ប.ទ/ស.ក.ប.ទ នឹងអាចប្រមូលចំនួន ច្រើនទៀតសំរាប់ប្រើប្រាស់នូវមូលនិធិបំរុងសំរាប់ការជួសជុល ឬការកែលំអរខ្នាតធំ។

**២.៣. ការត្រួតពិនិត្យ និងការកត់ត្រាលើការប្រើប្រាស់ធនធានៈ**

ការប្រើមូលនិធិខុសទិសដៅ ឬការអាក់ខានមិនបានបង់វិភាគទានរបស់សមាជិក ក.ក.ប.ទ/ស.ក.ប.ទ ចំពោះសកម្មភាព ថែទាំអាចជាគ្រោះថ្នាក់យ៉ាងធំធេងដល់ការសំរេចរបស់ ក.ក.ប.ទ/ស.ក.ប.ទ នេះ។ ក.ក.ប.ទ/ស.ក.ប.ទ មានសារៈសំខាន់ណាស់ ក្នុងការថែរក្សាកំណត់ហេតុពីការប្រមូលធនធានទាំងអស់ ដូចជាប្រាក់ ការចំណាយតាមការស្ម័គ្រចិត្ត ពលកម្ម សំភារៈ ។ល។ ក.ក.ប.ទ/ស.ក.ប.ទ គួររក្សាដោយប្រុងប្រយ័ត្ននូវការចំណាយ រួមមានការចំណាយសំរាប់ ពលកម្ម ឬ សំភារៈ ការរួមវិភាគទានជាពលកម្មដោយសមាជិកសំរាប់ការងារថែទាំ។ល។ មានតែសមាជិក របស់របស់គណៈកម្មាធិការគ្រប់គ្រង ក.ក.ប.ទ/ស.ក.ប.ទ ប៉ុណ្ណោះដែលគួរធ្វើការចំណាយសំរាប់ការងារនេះ។ ការងារ នេះត្រូវបានធ្វើដោយមានវត្តមាននៃសមាជិក ក.ក.ប.ទ/ស.ក.ប.ទ យ៉ាងតិចពីរនាក់។ គណៈកម្មាធិការគ្រប់គ្រង ក.ក.ប.ទ/ស.ក.ប.ទ

ត្រូវរក្សាបង្កាន់ដៃសំរាប់ការចំណាយនិមួយៗ កំណត់ហេតុក្នុងសៀវភៅកំណត់ហេតុគ្រប់គ្រងធនធានដែលត្រូវរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព ។ជាការល្អត្រូវមានកំណត់ហេតុចម្លងពីរច្បាប់ដែលរក្សាទុកក្នុងកន្លែងដែលមានសុវត្ថិភាពពីរកន្លែង ។

## ៣. សវនកម្មនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

ប្រហែលម្តងក្នុង១ឆ្នាំដែលក្រុមទ្រទ្រង់ ក.ក.ប.ទ/ស.ក.ប.ទ ជាមួយសមាជិក និង គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវធ្វើសវនកម្ម ។ សវនកម្មនេះគួររួមបញ្ចូលការពិនិត្យលើ:

- ផែនការសេវាកម្មស្រោចស្រពរបស់ ក.ក.ប.ទ/ស.ក.ប.ទ
- ការអនុវត្តន៏ផែនការសេវាកម្ម រួមមានការផ្តល់ទឹក និងការដោះទឹកចេញ ការថែទាំ និងហិរញ្ញប្បទាន
- កំណត់ហេតុរបស់ ក.ក.ប.ទ/ស.ក.ប.ទ សំរាប់ការថែទាំ ការប្រមូល និង ការប្រើប្រាស់ធនធាន
- ដើរទស្សនៈកិច្ចដើម្បីត្រួតពិនិត្យមើលគុណភាពនៃការងារថែទាំ និងលក្ខខ័ណ្ឌដំណើរការរបស់ប្រព័ន្ធ
- សម្ភាសជាមួយកសិករដើម្បីអោយដឹងថាគណៈកម្មាធិការក.ក.ប.ទ/ស.ក.ប.ទ អនុវត្តតាមនិតិវិធីប្រជាធិបតេយ្យ និងបទបញ្ញត្តិរបស់ខ្លួនឬទេ និងដើម្បីអោយដឹងថា គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ នៅតែមានការគាំទ្រពីសមាជិករបស់ខ្លួនដែរឬទេ ។

## ៤. ផែនការសេវាកម្មស្រោចស្រព និងថ្លៃសេវាកម្មស្រោចស្រព

### ៤.១. ផែនការសេវាកម្មស្រោចស្រព

ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមួយអាចចែកចេញជាការផ្តល់សេវាកម្មបឋមពីរ និង សេវាកម្មគាំទ្រសំខាន់ពីរ ។ សេវាបឋមពីរគឺការផ្តល់ទឹក និងការបញ្ចេញទឹក ។ សេវាកម្មគាំទ្រសំខាន់ពីរគឺការគ្រប់គ្រងលើកិច្ចដំណើរការ ការថែទាំ និង ហិរញ្ញវត្ថុ ។ គោលបំណងរបស់ PIMD គឺដើម្បីធានានូវគណនេយ្យភាពរវាងអ្នកប្រើប្រាស់ទឹក គណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ និងរដ្ឋាភិបាលសំរាប់សេវាកម្មប្រព័ន្ធធារាសាស្ត្រ ។ សេវាកម្មប្រព័ន្ធធារាសាស្ត្រគឺជាធាតុសំខាន់មួយក្នុងការធានានូវគណនេយ្យភាពសំរាប់សេវាកម្មប្រព័ន្ធធារាសាស្ត្រ ។ ISP អាចជួយអោយមានភាពច្បាស់លាស់ដល់គោលបំណងសំខាន់ៗនៃប្រព័ន្ធធារាសាស្ត្រ ចំណែកឯសេវាកម្មផ្តល់ទឹក បង្ហូរ ថែទាំ និង សេវាកម្មគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ នឹងធានាឱ្យសំរេចនូវគោលបំណងទាំងនោះ ។ នៅពេលចាប់ផ្តើមរៀបចំ ISP គួរមានសេចក្តីថ្លែងការមួយដែលងាយយល់អំពីប្រភេទពូជដំណាំ(កំណត់រយៈពេលនិងទំហំ) អំពីគោលការណ៏ជាមូលដ្ឋាននៃការចែកចាយទឹកដែលត្រូវធ្វើកាលបរិច្ឆេទ ដើម្បីចាប់ផ្តើម-បញ្ចប់ រដូវស្រោចស្រពសេវាកម្មប្រព័ន្ធធារាស្ត្រ និងការបង្ហូរទឹកដែលត្រូវបានផ្តល់សកម្មភាពថែទាំជួសជុល និងកែលំអរត្រូវបានអនុវត្តរបៀបផ្តល់សេវាកម្មទាំងនេះ តើនរណានឹងផ្តល់? តម្លៃប៉ុន្មាន? វាត្រូវបង់ចំណាយដូចម្តេច? ។ ISP ត្រូវរៀបចំ ដើម្បីផ្តល់សេវាកម្មជាធម្មតាផែនការសេវាកម្មប្រព័ន្ធធារាសាស្ត្រ មានរយៈពេលមួយឆ្នាំ ។

**ខាងក្រោមនេះគឺជាខ្លឹមសារនៃផែនការសេវាកម្មស្រោចស្រព :**

១-ការអធិប្បាយអំពីគោលបំណងសេវាកម្មស្រោចស្រព ស្តង់ដារ និងលក្ខណៈវិនិច្ឆ័យ។ ការអធិបាយរួមមានពេលវេលា និងទីកន្លែង(តំបន់ដាំដុះ) សំរាប់ធ្វើការសំរេចប្រើប្រាស់ប្រភេទពូជនៅក្នុងប្រព័ន្ធធារាសាស្ត្រ និងអំពីរបៀបនៃការផ្តល់ និងចែកចាយដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកស្រោចស្រពរបស់ដំណាំដែល នឹងផ្តល់ដោយប្រព័ន្ធធារាសាស្ត្រ។

២-ការបញ្ជាក់ច្បាស់លាស់នៃសេវាកម្មសំរាប់ការដោះទឹកចេញ និងផ្តល់ទឹកស្រោចស្រព

- ទីកន្លែងដែលត្រូវផ្តល់ទឹក
- វិធីសាស្ត្រចែកចាយទឹក(រួមមានមូលដ្ឋានសំរាប់ចែកចាយទឹក ផ្តល់អាទិភាព និងប្រព័ន្ធចែកតាមលំដាប់លេខរៀង)
- កម្មវិធីចែកចាយទឹក (រួមមានកាលបរិច្ឆេទ តម្លៃ រយៈពេល និងបរិមាណទឹកដែលត្រូវផ្តល់)
- តម្រូវការបរិមាណទឹក

៣-ការបញ្ជាក់ច្បាស់លាស់នៃសេវាកម្មថែទាំ

- លក្ខខ័ណ្ឌដែលអាចទទួលយកបានសំរាប់ប្រភេទសំណង់នីមួយៗ
- ទីកន្លែង ប្រភេទ និងកំរិតប្រឡាយដែលត្រូវសំអាត
- បរិមាណដីល្បាប់ដែលត្រូវសំអាត
- ទីកន្លែង ប្រភេទ និងកំរិតការងារដែលត្រូវជួសជុល
- ការបូមខ្លាញ់ លាបថ្នាំ និងតម្រូវការថែទាំផ្សេងៗទៀតសំរាប់សំណង់ត្រួតពិនិត្យ និងឧបករណ៍វាស់ស្ទង់ទឹក។

៤-កាតព្វកិច្ចសំរាប់ការចែករំលែកតម្លៃ

- មូលដ្ឋានសំរាប់កំណត់តម្លៃដល់សមាជិក បុគ្គលិករបស់ ក.ក.ប.ទ/ស.ក.ប.ទ
- ចំនួនថ្ងៃពលកម្មដែលត្រូវរួមវិភាគទានដោយសមាជិក ក.ក.ប.ទ/ស.ក.ប.ទ
- ចំនួនសំភារៈដែលត្រូវរួមវិភាគទានដោយសមាជិក ក.ក.ប.ទ/ស.ក.ប.ទ (ខ្សាច់ ថ្ម ។ល។)
- ការបង់ ចំណាយដោយសមាជិក ក.ក.ប.ទ/ស.ក.ប.ទ (ទឹកប្រាក់ ឬការចែករំលែកផលិតផល)
- ប្រភេទ និងចំនួនបុគ្គលិក ក.ក.ប.ទ/ស.ក.ប.ទ ដែលបានតែងតាំងក្នុងមុខងារ និងទីកន្លែង
- ចំនួនថវិការរបស់ក្រសួងធនធានទឹកនិងឧតុ និយមដែលផ្តល់សំរាប់ការសាងសង់សំណង់(ប្រសិនបើមាន)

៥-កាតព្វកិច្ចរដ្ឋបាល

-តម្រូវការត្រួតពិនិត្យ តាមដាន និងរាយការណ៍

-រក្សាទុកនូវកំណត់ហេតុប្រជុំ និងគណនេយ្យ

-និតិវិធីតាមលិទ្ធិប្រជាធិបតេយ្យសំរាប់ធ្វើសេចក្តីសំរេចចិត្តរបស់ ក.ក.ប.ទ/ស.ក.ប.ទ

-តម្រូវការដោះ ស្រាយជម្លោះ

-រៀបចំកម្មវិធី និងកិច្ចការសំរាប់សវនកម្មគ្រប់គ្រងប្រព័ន្ធធារាស្ត្រ

### ៤.២. ការរៀបចំផែនការស្រោចស្រពនៅតាមប្លុក

ជំហានដំបូងគឺប្រធានអនុក្រុម ឬ ប្រធានក្រុម រៀបចំប្រជុំនៅតាមប្លុក ។ម្ចាស់ស្រែនៅតាមប្លុកប្រជុំជាមួយគ្នា ដើម្បីពិភាក្សាពីផែនការរបស់ពួកគេសំរាប់រដូវបង្កបង្កើនផលបន្ទាប់ ។ផែនការត្រូវរួមបញ្ចូលជាមួយនឹងប្រភេទនៃដំណាំកំពង់ដាំដុះ និងតំបន់ដែលត្រូវដកស្ទូង។ ផែនការសេវាកម្មស្រោចស្រពនៅកំរិតនេះគួរចង្អុលបង្ហាញពីថ្ងៃ ខែសំរាប់រៀបចំដី សាប ដកស្ទូង និងកាលវិភាគស្រោចស្រពប្រចាំឆ្នាំ បន្ទាប់មកបរិមាណទឹកត្រូវបានប្រែប្រួលផងដែរដោយយោងទៅលើរូបមន្តខាងលើ និងផ្អែកទៅលើតម្រូវការទឹករបស់ដំណាំដែលត្រូវបានអនុវត្តត្រឹមត្រូវទៅតំបន់ដាំដុះ ។

ផែនការសេវាកម្មស្រោចស្រពកំរិតប្លុកបានបញ្ចប់សំរាប់ប្លុកនិមួយៗម្តងមួយៗដែល ផែនការសេវាកម្ម ស្រោចបានបញ្ចូលនៅកំរិតអនុគំរោង។ ប្រធាន ក.ក.ប.ទ/ស.ក.ប.ទ និងអនុប្រធានជាមួយអ្នកដឹកនាំនៅតាមប្លុកត្រូវតែបង្កើតផែន ការកំរិតប្រព័ន្ធទាំងមូលដោយផ្អែកទៅលើផែនការតាមប្លុកខាងលើ។ បញ្ជីឈ្មោះប្លុកឯកជន (ប្រសិនបើមាន) និងត្រូវបានប្រើប្រាស់ទឹកផងដែរ ដើម្បីជួយស្រោចស្រង់ក្នុងមួយជីវិតដំណាំ គណនេយ្យត្រូវគិតពិចារណាហើយប្រមូលថ្លៃសេវាកម្មទឹក (ISF) ។

## ៥. ការគ្រប់គ្រងរដ្ឋបាល ក.ក.ប.ទ/ស.ក.ប.ទ

ការគ្រប់គ្រងរដ្ឋបាលរបស់ ក.ក.ប.ទ/ស.ក.ប.ទ គួរតែប្រើប្រាស់វិធីសាស្ត្រងាយៗនិងមានតម្លាភាពជាមួយសមាជិកទាំងអស់ ។ វាគឺជាកិច្ចការសំខាន់ដើម្បីបង្កើតឡើងនូវជំនឿ និងទំនុកចិត្ត ពិសមាជិកក្នុងការអនុវត្តសកម្មភាពរបស់ ក.ស.ក.ប.ទ ។

### ៥.១. ការងាររដ្ឋបាលដែលត្រូវធ្វើ:

- កិច្ចព្រមព្រៀងប្រចាំឆ្នាំជាមួយអ្នកផ្តល់សេវាកម្មស្រោចស្រព និងដោះទឹក។
- កិច្ចព្រមព្រៀងប្រចាំឆ្នាំក្នុងការផ្តល់សេវាកម្មទៅកសិករ ។
- កិច្ចព្រមព្រៀងប្រចាំឆ្នាំជាមួយអ្នកម៉ៅការ និងអ្នកផ្តល់សេវាកម្មផ្សេងៗ ។
- ចុះកិច្ចសន្យាជាមួយបុគ្គលិកជួលពីខាងក្រៅ ។
- កិច្ចព្រមព្រៀង ឬកិច្ចសន្យាជាមួយអ្នកដែលមិនមែនជាសមាជិក ។
- ចុះឈ្មោះសមាជិក ជាមួយ និងទីតាំង និងទំហំដីរបស់សមាជិក ។
- កត់ត្រាចំណូលចំណាយ បំណុល នៃសមាជិក ឬអ្នកដែលមិនមែនសមាជិក ។
- ធ្វើផែនទីផ្ទៃដី និងបណ្តាញទឹក និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ។

- កត់ត្រាសេវាកម្ម (បរិមាណទឹក ផ្ទៃដីដោះទឹក)
- ធ្វើកំណត់ហេតុប្រជុំ របាយការណ៍ ទិន្នផលប្រចាំឆ្នាំ ។
- កត់ត្រាសារពើភ័ណ្ឌប្រពន្ធ័ស្រោចស្រព
- ស្តុកសំភារៈ (សំភារៈការិយាល័យ សំភារៈបច្ចេកទេស...........)
- សៀវភៅលិខិតចេញចូល
- កសាងឯកសាររដ្ឋបាល និងលិខិតបទដ្ឋាននានា ។
- រក្សាឯកសារគ្រប់ប្រភេទ

**៥.២. ការប្រើប្រាស់ពាក្យពេចន៍ក្នុងការសរសេរលិខិតស្នាម**

១-ការចុះថ្ងៃ-ខែ-ឆ្នាំ

ក-ក្នុងករណីនៃការសរសេរលិខិតរដ្ឋបាលណាមួយជូនទៅនរណាម្នាក់ដែលមានឋានៈ និងតួនាទីធំជាម្ចាស់លិខិតត្រូវដាក់ថ្ងៃ-ខែ-ឆ្នាំ ដូចឧទាហរណ៍ខាងក្រោមៈ

# ផ្នែកទី ៧_ ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១- ការសរសេរលិខិតរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុក....................
ក្រុមកសិករប្រើប្រាស់ទឹក...............
លេខ :...................ក.ក.ប.ទ ....................　　ថ្ងៃទី ........... ខែ ........... ឆ្នាំ

ខ-ក្នុងករណីនៃការសរសេរលិខិតរដ្ឋបាលណាមួយជូនទៅនរណាម្នាក់ដែលមានឋានៈតួនាទីតូចជាម្ចាស់ លិខិត ត្រូវដាក់ថ្ងៃ-ខែ-ឆ្នាំ ដូចឧទាហរណ៍ខាងក្រោម:

.....................................................................................................................................
សេចក្តីដូចបានជំរាបជូនខាងលើ ខ្ញុំសូមឯកឧត្តម/.......... /លោក ........... មេត្តា..............
ពាមការគួរ
សូមឯកឧត្តម/.......... /លោក ........... មេត្តាទទួលនូវការគោរព/រាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។
.............. ថ្ងៃទី ........ ខែ ........... ឆ្នាំ............
ប្រធាន

គ-រាល់របាយការណ៍ផ្សេងៗ លិខិតអញ្ជើញ លិខិតទទួល/លិខិតប្រគល់សម្ភារៈ ថ្ងៃ-ខែ-ឆ្នាំ ត្រូវដាក់នៅ ខាងក្រោម និងខាងស្តាំដៃ ដូចបង្ហាញក្នុងឧទាហរណ៍ខាងក្រោម :

.....................................................................................................................................
........... ថ្ងៃទី ...... ខែ....... ឆ្នាំ .........
បានឃើញ និងឯកភាព　　អ្នកធ្វើរបាយការណ៍
**ប្រធាន**

**២-ការប្រើប្រាស់ពាក្យពេចន៍**

**ក-លិខិតផ្ញើរទៅកាន់អ្នកដែលមានបុណ្យស័ក្តិធំជាង :**

ក្នុងករណីនេះ ម្ចាស់លិខិតដែលមានតួនាទី/បុណ្យស័ក្តិតូច ទាបជាងអ្នកទទួល ត្រូវប្រើពាក្យពេចន៍ដូច ខាងក្រោម:

ក-សេចក្តីផ្តើម(ផ្នែកផ្តើម)

ប្រធានក្រុមកសិករប្រើប្រាស់ទឹក....................................

សូមគោរពជូន

ឯកឧត្តម................. / លោក................

កម្មវត្ថុ:...........................................................................................................................

ខ-រូបមន្តបញ្ចប់(សេចក្តីបញ្ចប់)

សេចក្តី/អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម ............../លោកប្រធាន................

មេត្តា ............................................................. ដោយអនុគ្រោះ។

សូមឯកឧត្តម/លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

..............ថ្ងៃទី......... ខែ ........ ឆ្នាំ........

ប្រធាន

(ហត្ថលេខា និងឈ្មោះ)

**គ-លិខិតផ្ញើរទៅកាន់អ្នកដែលមានបុណ្យស័ក្តតូចជាង :**

ម្ចាស់លិខិតដែលមានតួនាទី/បុណ្យស័ក្តិធំ ខ្ពស់ជាងអ្នកទទួល ត្រូវប្រើពាក្យពេចន៍ដូចខាងក្រោម:

ក-សេចក្ដីផ្ដើម(ផ្នែកផ្ដើម)

| |
|---|
| ប្រធានក្រុមកសិករប្រើប្រាស់ទឹក.................... <br> ជម្រាបមក <br> លោក................ <br> កម្មវត្ថុ:.................................................................................................................... |

ខ-រូបមន្តបញ្ចប់(សេចក្ដីបញ្ចប់)

| |
|---|
| សេចក្ដី/អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន................ <br> មេត្តា/ចាត់............................................................ ដោយអនុគ្រោះ ។ <br> លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ ។ <br> ..............ថ្ងៃទី......... ខែ ........ ឆ្នាំ........ <br> ប្រធាន <br> (ហត្ថលេខា និងឈ្មោះ) |

**គ-លិខិតផ្ញើរទៅកាន់អ្នកដែលមានបុណ្យស័ក្តិប្រហាក់ប្រហែលគ្នា :**

ក្នុងករណីនេះ ម្ចាស់លិខិតដែលមានតួនាទី/បុណ្យស័ក្តិប្រហាក់ប្រហែលគ្នាអ្នកទទួល ត្រូវប្រើពាក្យពេចន៍ដូចខាងក្រោម:

១-សេចក្ដីផ្ដើម(ផ្នែកផ្ដើម)

| |
|---|
| ប្រធានក្រុមកសិករប្រើប្រាស់ទឹក.................... <br> សូមគោរពជូន/សូមជម្រាបជូន/គោរពជូន/ជំរាបមក <br> លោក................ <br> កម្មវត្ថុ:.................................................................................................................... |

២-រូបមន្តបញ្ចប់ (សេចក្តីបញ្ចប់)

| |
|---|
| សេចក្តី/អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម/លោកប្រធាន............... |
| មេត្តា/ចាត់..........................................................ដោយអនុគ្រោះ ។ |
| សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។ |
| ប្រធាន |
| (ហត្ថលេខា និងឈ្មោះ) |

ចំណាំៈ ក្នុងករណីនេះការចុះថ្ងៃ-ខែ-ឆ្នាំ អាចដាក់ខាងលើឬខាងក្រោមទៅតាមការយល់ឃើញរបស់ម្ចាស់លិខិតចំពោះអ្នកទទួល ។

**៤-គំរូផ្សេងៗ នៃលិខិតរដ្ឋបាល**

ក-ទម្រង់ទូទៅៈ

ដើម្បីតាក់តែងលិខិតអ្វីមួយយើងត្រូវពិនិត្យលើ :

១-ប្រភេទលិខិត

២-ផ្នែកនៃលិខិត

៣-តួនាទីរបស់អ្នកទទួល និងអ្នកសរសេរ

៤-ថ្នាក់ ឬឋានានុក្រមរបស់អ្នកទទួល និងអ្នកសរសេរ

ចំពោះអ្នករត់លិខិតស្នាមត្រូវប្រកាន់យកគោលការណ៍៣យ៉ាងគឺៈ

១-គុណភាព(នៅរក្សាភាពដើម មិនរហែក មិនប្រឡាក់ មិនបាក់ផ្នត់ .......... )

២-សុវត្ថិភាព(មិនបាត់បង់ / បាត់សន្លឹក ........ )

៣-ប្រសិទ្ធិភាព(ទាន់ពេលវេលា តាមកាលៈទេសៈ មិនយឺតយូរ អាចយកអនុវត្តបាន)

គោលការណ៍ ២ យ៉ាងដែលអ្នកគ្រប់គ្រងត្រូវធ្វើ

**១-ការងារបុគ្គលិក**

២-ការងារធានារ៉ាប់រងសង្គមបុគ្គលិក

៣-ការងារក្របខ័ណ្ឌ

៤-ការងារអភិវឌ្ឍន៍ធនធានមនុស្ស

**២-ការងារគ្រប់គ្រងសមាជិក**

១-ការងាររបៀប

២-ការងារពិធីការ

៣-ការងារតាក់តែងលិខិតស្នាម និងបូកសរុប

៤-ការងារសណ្តាប់ធ្នាប់ សន្តិសុខ អនាម័យទីធ្លា ថែទាំ

៥-ការងារឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ

## ឧបសម្ព័ន្ធទី២_ គំរូលិខិត ប្រធានគណៈកម្មការ ស,ក,ប,ទ

ខ-គំរូលិខិតមួយចំនួន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្រុក :** .........................

ក្រុមកសិករប្រើប្រាស់ទឹក .............

លេខ : ................ ក.ក.ប.ទ/ ......................                                    ........... ថ្ងៃទី........ ខែ ....... ឆ្នាំ........

**ប្រធានគណៈកម្មាធិការ ក.ក.ប.ទ/............**

**គោរពជូន**

**ឯកឧត្តម/លោក**

**កម្មវត្ថុ:** ........................................................................................................................

**យោង:** លិខិត ...................................................................................................................

........................................................................................................................................

**ឯកសារភ្ជាប់:** គម្រោងសាងសង់...........................................................................................

........................................................................................... ....................... ....................

តាមកម្មវត្ថុ យោង និងឯកសារភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម/លោកថា :

........................................................................................................................................

........................................................................................................................................

សូមឯកឧត្តម/លោក ............. មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ចម្លងជូន**

**ប្រធាន**

-..................................

-..................................

-..................................

## ឧបសម្ព័ន្ធទី៣.    របាយការណ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្រុក:** .........................

**ក្រុមកសិករប្រើប្រាស់ទឹក** ..................

លេខ : ................ ក.ក.ប.ទ/ ......................

## របាយការណ៍

ស្ដីពី ....................................................................................

អនុវត្តតាម ..............................................................................................................

កាលពីថ្ងៃទី......... ខែ........ ឆ្នាំ ........... នៅ ......................................................................

មានបើកការប្រជុំមួយក្រោមអធិបតីភាពឯកឧត្ដម/លោក .......................... ឋានៈ ..................................

សមាសភាពចូលរួមមាន :

លោក ..................................................

លោក ..................................................

អវត្តមាន :

លោក ..................................................

ជាកិច្ចចាប់ផ្ដើមឯកឧត្ដម/លោក ...........................................................................................

ក្រោយពីពិភាក្សាល្អិតល្អន់ អង្គប្រជុំបានសម្រេចដូចតទៅ :

១-.....................................................................

២-.....................................................................

អង្គប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង .......... ថ្ងៃទី .......... ខែ .......... ឆ្នាំ ............ ដែលប្រកបដោយបរិយាកាសរីករាយ និងស្និទស្នាលបំផុត ។

បានឃើញ និងឯកភាព
ប្រធានអង្គប្រជុំ

ក.ក.ប.ទ.........ថ្ងៃទី...... ខែ....... ឆ្នាំ.......
អ្នកធ្វើរបាយការណ៍

## ឧបសម្ព័ន្ធទី៤- របាយការណ៍បូកសរុប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្រុក :** .........................

**ក្រុមកសិករប្រើប្រាស់ទឹក** ..................

លេខ : ................ ក.ក.ប.ទ/ .......................

### របាយការណ៍បូកសរុប
**ការិយាអនុភាព** .............................................
**ឆ្នាំ**........... **និងទិសដៅ** .........................

I-សភាពការណ៍រួម :

.................................................................................................................................

II-លទ្ធផលការងារអនុវត្តឆ្នាំ............. :

(វាយតម្លៃការងាយស្រួល និងការលំបាក)

១-គណ:កម្មាធិការ ក.ក.ប.ទ

.................................................................................................................................

២-គណ:កម្មាធិការ អ.ក.ប.ទ

.................................................................................................................................

III-ការសន្និដ្ឋាន :

.................................................................................................................................

IV-ទិសដៅ និងការអនុវត្តន៍ភារកិច្ចឆ្នាំ........... :

.................................................................................................................................

V-សំណូមពរ :

-បណ្តុះបណ្តាល ..........................................................................................................

-សាងសង់ការិយាល័យ ..................................................................................................

កន្លែងទទួល

- ...............................

កាលប្បវត្តិ-ឯកសារ

ក.ក.ប.ទ .........ថ្ងៃទី ...... ខែ...... ឆ្នាំ......

ប្រធាន

## ឧបសម្ព័ន្ធទី៥ របាយការណ៍សង្ខេប បេសកកម្ម របស់ ស,ក,ប,ទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ស្រុក :** .........................

**ក្រុមកសិករប្រើប្រាស់ទឹក** ..................

លេខ : ................ ក.ក.ប.ទ/ .......................

### របាយការណ៍

ស្តីពី ..................................................................................

យោងតាមលិខិតលេខ .......... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ .............. របស់ .........................
ស្តីពី ..........................................................................................................................................
សូមជម្រាបជូនលោក................ មេត្តាជ្រាបថា ខ្ញុំ(ឈ្មោះ) ...............................................................
ឋានៈ.......................................
រួមដំណើរដោយលោក(ឈ្មោះ) .............................. ឋានៈ .................................................................
បានចុះបេសកកម្មនៅខេត្ត/ក្រុង....................... ពីថ្ងៃទី........... ដល់ថ្ងៃទី ............ ខែ ......... ឆ្នាំ...............
ដើម្បី ...........................................................................................................................................
.....................................................................................................................................................
.....................................................................................................................................................
...................................................................................................................................................។

ក.ក.ប.ទ .............. ថ្ងៃទី ....... ខែ......... ឆ្នាំ.........

**ប្រធាន** (ចុះបេសកកម្ម)

## ឧបសម្ព័ន្ធទី៦ លិខិតអញ្ជើញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ស្រុក : .........................**
**ក្រុមកសិករប្រើប្រាស់ទឹក .............**

<u>លិខិតអញ្ជើញ</u>

ឈ្មោះ :.............................. សមាជិកក្រុមកសិករប្រើប្រាស់ទឹក ..................................................
អនុក្រុម :..............................................................ក្រុម : .....................................................
ដើម្បីចូលរួមប្រជុំ ឬវគ្គបណ្តុះបណ្តាលស្តីពី ..........................................................................
.............................................................................................................................................
នៅ............................................................... ម៉ោង ................. ថ្ងៃទី........... ខែ............... ឆ្នាំ ...

សូមអញ្ជើញចូលរួមតាមការកំណត់ជាកំហិត ។

ក.ក.ប.ទ............ ថ្ងៃទី........ ខែ....... ឆ្នាំ.........
ហត្ថលេខា

**ប្រធាន**

ឧបសម្ព័ន្ធទី៧ ៖

# យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា លើវិស័យធារាសាស្រ្ត

## ១- ទស្សនៈវិស័យលើវិស័យធារាសាស្រ្តកសិកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម

ក្រោមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅនិងយុទ្ធសាស្រ្តរហូតដល់ឆ្នាំ ២០១០ ពង្រីកអោយបានផ្ទៃដីស្រោចស្រពពី ២៥-៥០ ភាគរយនៃផ្ទៃដីដាំដុះសរុបសំរាប់សន្តិសុខស្បៀង និង បង្កើនប្រាក់ចំណូលគ្រួសារ GDP-Gross Domestic Production និងចំណូលជាតិ GNP- Gross Natonal Production ។

**១.១-យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យធារាសាស្រ្ត** (គោលនយោបាយជាតិ និងយុទ្ធសាស្រ្ត **PIMD**)

- លើកកំពស់វិស័យកសិកម្ម
- បង្កើនការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
- ការអភិវឌ្ឍន៍វិស័យឯកជន និង បង្កើតការងារ
- ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស

**១,២-ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តរបស់ក្រសួងធនធានទឹក និង ឧតុនិយម** NSDP (2006-2010)

យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាទទួលបានជោគជ័យ និងដើម្បីបានបង្ហាញច្បាស់ពី PIMD ។

**១,៣- គោលបំណងនៃការបង្កើតកសិករក្រុមអ្នកប្រើប្រាស់ទឹក**

- ធ្វើអោយប្រព័ន្ធធារាសាស្រ្តមាននិរន្តរភាព
- ដំណើរការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្រ្ត
- បង្កើនផលិតភាពកសិកម្ម កាត់បន្ថយការចំណាយរបស់រដ្ឋាភិបាលទៅលើកិច្ចដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្រ្ត ។

**ក- <u>ការផ្តល់អំណាច</u>**

- មានសិទ្ធិឈរឈ្មោះ និងបោះឆ្នោតជ្រើសរើសគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ដោយខ្លួនឯង
- រៀបចំលក្ខន្តិកៈ និងបទបញ្ញត្តិដោយខ្លួនឯង
- ការពារថែទាំ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្តរបស់ខ្លួន
- រកចំណូល និងធ្វើអាជីវកម្មក្នុងរង្វង់ ក.ក.ប.ទ/ស.ក.ប.ទ របស់ខ្លួន
- ជ្រើសរើស និងលប់ចោលអ្នកផ្តល់សេវាកម្មធារាសាស្រ្តកសិកម្ម និងការធ្វើអាជីវកម្មកសិកម្ម

- អនុវត្តការផ្តល់អំណាចជាបណ្តើរៗ

(តាមច្បាប់ប្រទេសដែលមានស្រាប់) ក្នុងដំណាក់កាលលក្ខន្តិកៈ ក.ក.ប.ទ/ស.ក.ប.ទ កំពុងរៀបចំ។

- ក.ក.ប.ទ/ស.ក.ប.ទ ជាអង្គភាពស្របច្បាប់ ឯករាជ្យ អំណាចសិទ្ធិសំរេច មានសិទ្ធិធ្វើការទំនាក់ទំនង សុំជំនួយហិរញ្ញវត្ថុ បច្ចេកទេសពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសប្បុរសជននានា។
- ក.ក.ប.ទ/ស.ក.ប.ទ មួយត្រូវគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមួយ។

ខ- <u>**អភិបាលកិច្ច**</u>

- ភាពជាម្ចាស់ គឺជាការប្រមូលផ្តុំនូវធនធានសាធារណៈរបស់រដ្ឋដើម្បីចែកចាយ និងបែងចែកពីថ្នាក់ កណ្តាលទៅថ្នាក់ក្រោម
- ជាចំណាត់ថ្នាក់នៃនយោបាយ,សង្គម,សេដ្ឋកិច្ចនិងប្រព័ន្ធរដ្ឋបាលដែលមាននៅនឹងកន្លែង ដើម្បីការ អភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកនិងផ្តល់នូវសេវាកម្មធនធានទឹកទៅដល់គ្រប់កំរិតនៃមនុស្សក្នុងសង្គម។
- អភិបាលកិច្ចល្អតំរូវអោយមានតម្លាភាព គណនេយ្យភាព សមធម៌ ការទទួលយកនូវបញ្ហាសង្គមមូលដ្ឋាន នៃនិរន្តរភាពក្នុងការអនុវត្តន៍ ការព្រមព្រៀង និងពិភាក្សាក្នុងការធ្វើសេចក្តីសំរេចចិត្ត។
- វិមជ្ឈការគឺជាដំណើរការផ្ទេរនូវសមាសធាតុនៃការគ្រប់គ្រង និង សេវាធនធានទឹក ពីថ្នាក់កណ្តាលរបស់រដ្ឋាភិបាលទៅថ្នាក់ខេត្ត, តំបន់, មូលដ្ឋាន។
- សមាសធាតុនៃការទំនាក់ទំនង និងគ្រប់គ្រងទំនាស់ យើងបានឃើញថាការទំនាក់ទំនង គឺវាមានសារៈសំខាន់សំរាប់ប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន ដើម្បី :
    - ➢ ចែករំលែកចំណេះដឹង
    - ➢ ជារបាំងទប់ស្កាត់ភាពអនាធិបតេយ្យ
    - ➢ កាត់បន្ថយចំណាយរដ្ឋបាល
    - ➢ ធ្វើអោយប្រសើរឡើងនូវការអនុវត្តន៍
    - ➢ កំណត់ និងដោះស្រាយបញ្ហា
    - ➢ កសាងសមត្ថភាព

**១,៤- តើត្រូវធ្វើដូចម្តេច ដើម្បីសំរេចគោលនយោបាយ PIMD**

ដើម្បីបន្ថែមពីលើអ្វីដែលមានស្រាប់ និងអោយបានគ្រប់ជ្រុងជ្រោយនៃផ្លូវច្បាប់ ដើម្បីអោយមានភាពងាយស្រួលក្នុងការអនុវត្តន៍ ប្រកបដោយប្រសិទ្ធិភាពដូចខាងក្រោម

- អនុក្រិតស្តីពីសហគមន៍កសិករប្រើប្រាស់ទឹក
- ប្រកាសស្តីពី ការផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

- លិខិតបទដ្ឋានគតិយុទ្ធដទៃទៀតដែលបំរើដល់ភាពល្អូតលាស់នៃសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់សមាជិក ក.ក.ប.ទ/ស.ក.ប.ទ ដូចដែលបានរៀបរាប់ពីគោលដៅនៃការអនុវត្តន៍គោលនយោបាយ **PIMD** ចង់បាន ។

**១,៥- ខ្លឹមសារ និង អត្ថន័យនៃការចូមលរួមគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និង កិច្ចអភិវឌ្ឍន៍ PIMD**

- កសិករជាអ្នកទទួលផលពីប្រព័ន្ធធារាសាស្ត្រត្រូវចាត់ទុកថាប្រព័ន្ធធារាសាស្ត្រជារបស់ខ្លួន ពីព្រោះខ្លួនគេត្រូវបានទទួលផលប្រយោជន៍ពីប្រព័ន្ធធារាសាស្ត្រ ដើម្បីស្ថេរភាពនៃការទ្រទ្រង់ជីវិតរស់នៅ និងបានកែប្រែជីវភាពរស់នៅរបស់ខ្លួនគេឱ្យបានប្រសើរឡើងជាបន្តបន្ទាប់ ។
- ដើម្បីធ្វើវិមជ្ឈការនៃការគ្រប់គ្រងចាត់ចែង និង ធ្វើសេចក្តីសំរេចចិត្ត ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ និងសំរេចចិត្តក្នុងកិច្ចការដទៃទៀតដើម្បីធ្វើឱ្យមានផលកំរៃ រឺ ប្រាក់ចំណូលសមរម្យនិងប្រសើរឡើងជាបន្តបន្ទាប់ទៅតាមច្បាប់កំណត់ ។
- ឱ្យរដ្ឋាភិបាលអាចជួយទៅដល់កសិករចំគោលដៅ នៃគោលបំណងនៃការចង់បានរបស់កសិករ
- ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រដែលបានសាងសង់រួចហើយនោះ មានម្ចាស់ការពារថែទាំ និងធ្វើឱ្យមាននិរន្តរភាពក្នុងការប្រើប្រាស់ ដែលមិនធ្វើឱ្យរដ្ឋាភិបាលយកថវិកាដែលមានទៅជួសជុល រឺសាងសង់ហេដ្ឋារចនា សម្ព័ន្ធស្រោចស្រពដែលបានធ្វើរួចហើយនោះទេ និងជាប្រការមួយដ៏ល្អធ្វើឱ្យមានលទ្ធភាពយកថវិកាដែលមាននេះ ទៅធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ព្រមទាំងពង្រីកបន្ថែមទៀតជាបន្តបន្ទាប់នូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពទៅតាមតំរូវការរបស់ប្រព័ន្ធធារាសាស្ត្រ ។
- ដើម្បីគៀងគរនូវការចូលរួមពីគ្រប់មហាជនឱ្យបានយល់ច្បាស់នូវអត្ថប្រយោជន៍ ដូចដែលបានរៀបរាប់ និងគាំទ្រយ៉ាងសកម្ម និងដោយឆន្ទៈមុះមុត ដើម្បីធ្វើឱ្យកសិករអ្នកទទួលផលមានផលរបរ មួយជាអចិន្ត្រៃយ៍នៅក្នុងមូលដ្ឋានរបស់ខ្លួនធ្វើឱ្យជៀសវាងបាននូវចំណាកស្រុក ដែលធ្វើឱ្យប៉ះពាល់លើទិដ្ឋភាពជាច្រើននៃសុខមាលភាពសង្គម និងជីវភាពរស់នៅធ្វើឱ្យម្ចាស់ជំនួយទាំងក្នុងនិងក្រៅប្រទេស ទាំងស្ថាប័នហិរញ្ញវត្ថុ និងបណ្តាសមីប្រទេសមានការទុកចិត្តយ៉ាងប្រាកដនូវកំណើនទិន្នផល និងផលិតផល ដែលធ្វើឱ្យមានកំណើនសេដ្ឋកិច្ចគ្រួសារ និងធ្វើឱ្យមានកំណើនសេដ្ឋកិច្ចជាតិខ្ពស់ ដែលជាលទ្ធផលគឺមានថវិកា ដើម្បីសងរំលោះទៅបណ្តាស្ថាប័នហិរញ្ញវត្ថុ រឺម្ចាស់ជំនួយទាំងនោះ ។
- ធ្វើឱ្យលទ្ធភាពនៃការពង្រីកការផ្តល់ថវិកាពីម្ចាស់ជំនួយទាំងក្នុង និងក្រៅប្រទេស ទាំងស្ថាប័នហិរញ្ញវត្ថុ និងបណ្តាសម៉ីប្រទេសលើវិស័យធារាសាស្ត្រកសិកម្មកាន់តែទ្វេរឡើង ។

១,៦- តើត្រូវធ្វើដូចម្តេច ដើម្បីអនុវត្តឱ្យបានដូចគោលបំណងនេះ ?

*ក- អ្វីដែលកសិករត្រូវបំពេញតួនាទី*

ដូចដែលបានដឹងហើយគោលបំណងនៃគោលនយោបាយ PIMDនេះ គឺដើម្បីនិរន្តរភាពប្រព័ន្ធធារាសាស្ត្រនោះ ទើបអភិវឌ្ឍជីវភាពរស់នៅឱ្យមានប្រាក់ចំណូលសមរម្យ និងកើនឡើងជាបន្តបន្ទាប់សំរាប់កសិករអ្នកទទួលផលពីប្រព័ន្ធធារាសាស្ត្រ ដូច្នេះការចូលរួមខិតខំដោយឆន្ទះមោះមុតពីកសិករអ្នកទទួលផលខ្លួនឯង គឺជាកិច្ចការ សំខាន់បំផុតក្នុងចំណោមកិច្ចការសំខាន់ៗដទៃទៀត។

- កសិករម្នាក់ៗត្រូវតែគិតថាប្រព័ន្ធធារាសាស្ត្រនេះ គឺជាដើមទុនរបស់ខ្លួន ដើម្បីបង្កើននូវកំរិតជីវភាពរស់នៅរបស់ខ្លួនឱ្យបានធូរធារសមរម្យ ។
- កសិករម្នាក់ៗត្រូវតែគិតថាប្រព័ន្ធធារាសាស្ត្រនេះជារបស់ខ្លួន បំរើផលប្រយោជន៍របស់ខ្លួន ជាជីវិតរបស់ខ្លួន និងកូនចៅរបស់ខ្លួន ។
- កសិករម្នាក់ៗមិនត្រឹមតែការពារថែទាំតែខ្លួនឯងប៉ុណ្ណោះទេ ត្រូវតែបំផុសដល់អ្នកដទៃទៀតឱ្យចូលរួមការពារថែទាំដូចដែលខ្លួនបានធ្វើយ៉ាងដូច្នេះដែរ ។
- កសិករត្រូវតែសាមគ្គីគ្នាជាធ្លុងមួយនៅក្នុងការងារថែទាំហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីផលិតកម្មកសិកម្ម ដោយគិតផលប្រយោជន៍រួមជាធំ ហើយត្រូវតែចែកផលប្រយោជន៍នោះដោយស្មើមុខទៅតាមការចំណាយធនធាន និងពលកម្មដោយបុគ្គលនិមួយៗ និងមានតំលាភាព ។
- កសិករត្រូវតែបង្កើតឱ្យមានខ្សែសង្វាក់ផលិតកម្មកសិកម្មជាអចិន្ត្រៃយ៍នៅកន្លែងដែលមានធនធានទឹកគ្រប់គ្រាន់។ នៅកន្លែងដែលធនធានទឹកមិនទាន់គ្រប់គ្រាន់ត្រូវចេះច្នៃប្រឌិត ដាំដុះដំណាំណាដែលមិនត្រូវការទឹកច្រើន រៀបចំចងក្រងឱ្យទៅជាយន្តការរបស់ ក.ក.ប.ទ/ស.ក.ប.ទ ដោយកសិករអ្នកប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រខ្លួនឯង ដោយគ្រាន់តែទទួលការណែនាំផ្តល់យោបល់ និងសម្របសម្រួលដោយមន្ត្រីជំនាញលើការងារ ក.ក.ប.ទ/ស.ក.ប.ទ និង PIMD ។
- កសិករអ្នកទទួលផលទាំងអស់ត្រូវចូលរួមក្នុងការស្តារ រឺ សាងសង់ឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រជាមួយនឹងរដ្ឋាភិបាល ទាំងការកំណត់ទីតាំងស្នើនូវអ្វីដែលខ្លួនចង់បានជាអាទិភាព និងចូលរួម ជាធនធាន និងពលកម្ម ដើម្បីជាការដាក់ទុនជាមួយនឹងរដ្ឋាភិបាលជាពិសេសលើកទឹកចិត្តដល់ម្ចាស់ជំនួយឱ្យមានជំនឿ និងមិនខ្លាចរអារក្នុងការដាក់ទុនវិនិយោគរបស់គេ រឺផ្តល់ប្រាក់កម្ចីសម្បទានដល់ ក.ក.ប.ទ/ស.ក.ប.ទ។
- កសិករខ្លួនឯងត្រូវតែចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែលបានរៀបចំឡើងដោយស្ថាប័នបច្ចេកទេស ទាំងអស់។
- កសិករខ្លួនឯងត្រូវតែចូលរួមក្នុងកិច្ចប្រជុំនានា និងត្រូវមានយោបល់ចូលរួមគ្រប់កិច្ចការទាំងអស់ដែល ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ក.ក.ប.ទ/ស.ក.ប.ទ និងរៀបចំលក្ខន្តិកៈ និងបទបញ្ជាសំរាប់ ក.ក.ប.ទ/ស.ក.ប.ទ របស់ខ្លួន និងត្រូវតែអនុវត្តគ្រប់សមាជិក ក.ក.ប.ទ/ស.ក.ប.ទ ទាំងអស់មិនអាចលើកលែងបាន។
- កសិករត្រូវបង្កើតឱ្យមានក្រុមផលិតឱ្យបានច្រើនជាបន្តបន្ទាប់ដោយសាកល្បងពីមួយរឺពីរក្រុមផលិត

(ឧទា ហរណ៍ ក្រុមផលិតបន្លែ រឺក្រុមចិញ្ចឹមត្រី រឺក្រុមចិញ្ចឹមមាន់ រឺក្រុមផលិតផ្សិត ) ។ល។

- ការបង់ថ្លៃសេវាកម្មប្រព័ន្ធធារាសាស្ត្រដោយសមាជិកឬមិនសមាជិកដែលបានប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ត្រូវធ្វើឱ្យបានតាមចំនួនកំណត់តាមពេលវេលា និងត្រូវតែបង់គ្រប់ៗគ្នាមិនអាចខាន រឺ លើកលែងបាន ចំពោះគណៈកម្មាធិការ ក.ក.ប.ទ/ស.ក.ប.ទ ត្រូវតែរៀបចំធ្វើផែនការ ដើម្បីឱ្យមានសកម្មភាពជារៀងរាល់ថ្ងៃ ទោះបីមិនជារយៈពេលដាំដុះ រឺច្រូតកាត់ក៏ដោយដូចជាការធ្វើឥណទានសាច់ប្រាក់ ឥណទានពូជ-ជី ឥណទានសំភារៈ កសិកម្ម ។ល។

- ត្រូវមានថវិកាសម្រាប់ចូលរួមធ្វើទំនើបកម្មប្រព័ន្ធធារាសាស្ត្រជាមួយរដ្ឋាភិបាល ដើម្បីសម្រួលនិងធ្វើឱ្យរឹតតែមានប្រសិទ្ធិភាពខ្ពស់លើការប្រើទឹកស្រោចស្រព បម្រើដល់ភាពលូតលាស់នៃវិស័យកសិកម្ម ជាមួយនឹងកាលានុវត្តភាព ។

- ត្រូវមានថវិកាជួយចូលរួមតម្លៃលើកិច្ចដំណើរការការជួសជុលថែទាំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រក្នុងរយៈពេល៥ឆ្នាំជាមួយរដ្ឋាភិបាល និង មានថវិកាគ្រប់គ្រាន់សំរាប់រយៈពេល៥ឆ្នាំក្រោយ ដើម្បីឱ្យរដ្ឋាភិបាលអាចផ្ទេរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រជូន ក.ក.ប.ទ/ស.ក.ប.ទ ។

ខ- **<u>អ្វីដែលរដ្ឋាភិបាលត្រូវបំពេញតួនាទី</u>**

- ត្រូវរៀបចំស្តារ រឺសាងសង់ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ដែលបានខូចខាត រឺ សាងសង់បន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលចាំបាច់ ។
- បណ្តុះបណ្តាលកសាងសមត្ថភាពដល់អ្នកទទួលផលពីប្រព័ន្ធធារាសាស្ត្រ ទាំងកិច្ចប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ និងកិច្ចការពាក់ព័ន្ធទាំងឡាយដល់ការធ្វើឱ្យប្រសើរឡើងលើបច្ចេកទេសដាំដុះ និងបច្ចេកទេសដទៃទៀត ក្នុងវិស័យកសិកម្មដែលនឹងត្រូវបានគាំទ្រដោយស្ថាប័នកសិកម្មរបស់រាជរដ្ឋាភិបាល ។ ប្រាក់ដែលបានមកពីថ្លៃសេវាកម្មនេះ អាចអនុញ្ញាតិយកទៅធ្វើជាជំនួយឥណទានទុនបង្វិលឱ្យក្រុមផលិតណាមួយដែលចង់ផលិត ដោយចូលរួមជាមួយនឹងទុនផ្ទាល់ខ្លួននៃក្រុមផលិតនោះ ។
- ការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយនៃការចូលរួមពីស្ថាប័នពាក់ព័ន្ធ ហើយរដ្ឋាភិបាលត្រូវមានគោលនយោបាយដូចខាងក្រោម:
    - លើកទឹកចិត្តជាពិសេសដល់វិស័យឯកជនឱ្យចូលរួមវិនិយោគជាមួយ ក.ក.ប.ទ/ស.ក.ប.ទ ជាពិសេស ការធ្វើឯកជនភាវូបនីយកម្មនៅនឹងកន្លែង ។
    - ត្រូវមានគោលនយោបាយលើការកំនត់កិច្ចសន្យាទិញ-លក់ផលិតផលកសិកម្មពីសមាជិក ក.ក.ប.ទ/ស.ក.ប.ទ ។
    - ត្រូវមានគោលនយោបាយហិរញ្ញប្បទានប្រាក់កំចីកសិកម្មដល់កសិករ ដោយការប្រាក់ សម្បទាន ។

- ក្នុងស្ថានភាពមួយជាក់ស្តែងដែលក្រសួងធនធានទឹក និង ឧតុនិយម បានធ្វើការផ្តល់ចំណេះដឹងគ្រប់គ្រាន់ជាមួយនឹងថវិការបស់ ក.ក.ប.ទ/ស.ក.ប.ទ សមល្មមដែលអាចឱ្យ ក.ក.ប.ទ/ស.ក.ប.ទ មានលទ្ធភាពឈរដោយជំហរខ្លួនឯងបាន និងក្លាយជាអង្គភាពផលិតកម្មកសិកម្មមួយនៅឯមូល ដ្ឋានរបស់ខ្លួន ។
- ត្រូវធ្វើឱ្យកសិករមានការយល់ដឹងបន្ថែមទៀតលើការចូលរួមគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តាមរយៈ ការផ្សព្វផ្សាយជាលក្ខណៈរួម លក្ខណៈបុគ្គលដោយក្រុមផ្សព្វផ្សាយ និងបណ្តាញផ្សព្វផ្សាយ ។
- បង្កើតឱ្យបានបន្ថែមទៀតនូវប្រព័ន្ធធារាសាស្ត្រណាដែលពុំទាន់មាន ក.ក.ប.ទ/ស.ក.ប.ទ ដែលអាចបញ្ចៀសបាននូវជម្លោះចែកចាយទឹកមួយចំនួនធំ និងបង្កើននិរន្តរភាពក្នុងការប្រើប្រាស់ និង ជួសជុលថែទាំ ។
- ការធ្វើឱ្យមានប្រតិទិនបែងចែកទឹកឱ្យបានត្រឹមត្រូវនៅក្នុងគ្រប់ ក.ក.ប.ទ/ស.ក.ប.ទ ទាំងអស់ក្រោមការណែនាំពីមន្ត្រីបច្ចេកទេស ក.ក.ប.ទ/ស.ក.ប.ទ និងចូលរួមរៀបចំដោយ ក.ក.ប.ទ/ស.ក.ប.ទ ខ្លួនឯង ។
- ក្រុមការងារបច្ចេកទេសនឹងត្រូវទៅទំនាក់ទំនងធ្វើការជាប្រចាំដោយស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានចូលរួម ដោយផ្ទាល់ជាមួយ ក.ក.ប.ទ/ស.ក.ប.ទ

# សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

| ស្ថាប័ន | លេខទូរស័ព្ទ |
| --- | --- |
| ១- មជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្ត្រ | ០២៣ ២១៥ ៦៨៥ |
| ២- មន្ទីរធនធានទឹកខេត្ត កំពង់ស្ពឺ | ០១២ ៧០៩ ៥១៩ |
| ៣- មន្ទីរធនធានទឹកខេត្ត តាកែវ | ០៣២ ៩៣១ ៥៤៩ |
| ៤- មន្ទីរធនធានទឹកខេត្ត ព្រៃវែង | ០៤៣ ៩៤៤ ៥៦៧ |
| ៥- មន្ទីរធនធានទឹក ខេត្ត ស្វាយរៀង | ០៤៤ ៩៤៥ ៦៦៤ |
| ៦- មន្ទីរធនធានទឹកខេត្ត កំពង់ធំ | ០៦២ ៩៦២ ២៣៣ |
| ៧- មន្ទីរធនធានទឹកខេត្ត បន្ទាយមានជ័យ | ០៥៤ ៧១០ ៣៩៨ |
| ៨- មន្ទីរធនធានទឹកខេត្ត ឧត្តរមានជ័យ | ០៦៥ ៣៩២ ២២៧ |
| ៩- មន្ទីរធនធានទឹកខេត្ត ព្រះវិហារ | ០១៧ ២៧៧ ៥៦៧ |
| ១០- មន្ទីរធនធានទឹកខេត្ត សៀមរាប | ០៦៣ ៩៦៤ ៨២០ |
| ១១- មន្ទីរធនធានទឹកខេត្ត បាត់ដំបង | ០៥៣ ៧៣០ ៥១៣ |

**អាស័យដ្ឋានទំនាក់ទំនង**

ការិយាល័យតំណាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

ប្រចាំប្រទេសកម្ពុជា

គម្រោង :  GCP/CMB/033/EC

ផ្ទះលេខ ៥ ផ្លូវ ៣៧0 សង្កាត់បឹងកេងកង១ ចំការមន ភ្នំពេញ

ទូរស័ព្ទ :  +៨៥៥ (0) ២៣ ២១ ១៧ 0២ / ២១ ៦៥ ៦៦

ទូរសារ : +៨៥៥ (0)  ២៣ ២១ ៦៥ ៤៧

ប្រអប់សំបុត្រ : P.O.Box 53

វេបសាយ :   www. fao.org



**អាស័យដ្ឋានទំនាក់ទំនង**

មជ្ឈមណ្ឌលសេវាបច្ចេកទេស ប្រព័ន្ធធារាសាស្រ្ត នៃក្រសួង

ធនធានទឹក និង ឧតុនិយម

អគារលេខ ៣៦៤ វិថី មុនីវង្ស

ទូរស័ព្ទ :  + ៨៥៥ (0)  ២៣ ២១ ៥៦ ៨៥

ទូរសារ :  + ៨៥៥ (0)  ២៣ ២១ ៥៦ ៨៥


TURNING
THE RISING TIDE
OF HUNGER

FAO and EU Food Facility

www.fao.org/europeanunion